# ឯកសារចុងក្រោយមិនទាន់ផ្សព្វផ្សាយ

ចែកចាយ៖ ទូទៅ
២៤ សីហា ២០២០
ឯកសារដើម៖ អង់គ្លេស

## ក្រុមប្រឹក្សាសិទ្ធិមនុស្ស

**សម័យប្រជុំលើកទីសែសិបប្រាំ**
ថ្ងៃទី១៤ ខែកញ្ញា ដល់ថ្ងៃទី០២ ខែតុលា ឆ្នាំ២០២០
របៀបវារៈចំណុចទី២ និង ទី១០
**របាយការណ៍ប្រចាំឆ្នាំរបស់ឧត្ដមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស និងរបាយការណ៍របស់ការិយាល័យ ឧត្តមស្នងការ និងអគ្គលេខាធិការ**

**ការជួយឧបត្ថម្ភផ្នែកបច្ចេកទេស និងការកសាងសមត្ថភាព**

# ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា

## របាយការណ៍របស់អ្នករាយការណ៍ពិសេសស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា

*សេចក្ដីសង្ខេប*

អ្នករាយការណ៍ពិសេសស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា លោកស្រី រ៉ូណា ស្មីត ផ្ដល់ព័ត៌មានបច្ចុប្បន្នភាពស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា និងធ្វើការវិភាគអំពីផលប៉ះពាល់ខាងសិទ្ធិមនុស្សនៃការបន្តរាតត្បាតនៃជំងឺកូរ៉ូណា (ជំងឺកូវីដ-១៩)។ ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច-សង្គម គឺជាកង្វល់ជាពិសេស។ ការរឹតត្បិតទាក់ទងនឹងលំហប្រជាធិបតេយ្យ និងពលរដ្ឋ និងបញ្ហាសំខាន់ៗដែលមាននៅក្នុងរបាយការណ៍លើកមុននៅមិនទាន់ត្រូវបានដោះស្រាយនោះឡើយទេ។ អ្នករាយការណ៍ពិសេស ផ្ដល់អនុសាសន៍មួយចំនួន ដើម្បីដោះស្រាយបញ្ហាកង្វល់មួយចំនួនខាងសិទ្ធិមនុស្ស។

មាតិកា ទំព័រ

I. សេចក្តីផ្តើម ... 3
II. បរិបទ ... 4
III. ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ... 7
ក. លំហពលរដ្ឋ និងសេរីភាពមូលដ្ឋាន ... 7
ខ. សិទ្ធិដីធ្លី និងសិទ្ធិលំនៅដ្ឋាន ... 11
គ. ការមិនទុកនរណាម្នាក់ចោល ... 13
IV. សិទ្ធិមនុស្ស និងការឆ្លើយតបទៅនឹងជំងឺកូវីដ-១៩ ... 19
ក. ការរឹតត្បិតសិទ្ធិមនុស្ស ក្នុងបរិបទនៃការរីករាលដាលនៃជំងឺកូវីដ-១៩ ... 21
ខ. សិទ្ធិទទួលបានកម្រិតសុខភាពខ្ពស់បំផុត ... 21
គ. សិទ្ធិនារី ... 21
ឃ. ការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ ... 22
ង. សិទ្ធិធ្វើការ និងមានកម្រិតជីវភាពរស់នៅនៅសមរម្យ ... 23
V. អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ... 27
VI. ការចូលរួមរបស់ប្រទេសកម្ពុជាជាមួយយន្តការសិទ្ធិមនុស្ស ... 29
VII. ឧបាស្រ័យទៅរដ្ឋាភិបាល ... 32
VIII. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ... 33

## I. សេចក្តីផ្តើម

១. ដោយបានបញ្ជូនស្របតាមសេចក្តីសម្រេចចិត្តលេខ៤២/៣៧ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស របាយការណ៍នេះ មានបញ្ចូលព័ត៌មានថ្មីៗស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។ នៅក្នុងអំឡុងពេលពិនិត្យរបាយការណ៍នេះ (ចាប់ពីខែមិថុនា ឆ្នាំ២០១៩ ដល់ ខែមិថុនា ឆ្នាំ២០២០) អ្នករាយការណ៍ពិសេស បានបន្តឃ្លាំមើលស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។ ដោយសារតែការរីករាលដាននៃជំងឺកូរ៉ូណា (ជំងឺកូវីដ-១៩) និងដោយហេតុផលផ្នែកប្រតិបត្តិការផ្សេងទៀត ទាក់ទងនឹងការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ (ការិយាល័យ OHCHR) អ្នករាយការណ៍ពិសេស មិនអាចបំពេញបេសកកម្មទៅកាន់ប្រទេសបានទេ បន្ទាប់ពីការបន្តអាណត្តិរបស់លោកស្រីនៅក្នុងខែកញ្ញា ឆ្នាំ២០១៩។ រដ្ឋាភិបាលកម្ពុជា មិនអាចទទួលយកកាលបរិច្ឆេទសម្រាប់បេសកកម្មដែលបានស្នើឡើងនៅក្នុងត្រីមាសចុងក្រោយនៃ ឆ្នាំ២០១៩ ទេ។ ដំណើរទស្សនកិច្ចដែលបានគ្រោងធ្វើនៅខែមេសា ឆ្នាំ២០២០ ត្រូវបានលើកពេល។ នៅថ្ងៃទី២៤ ខែមិថុនា រដ្ឋាភិបាលបានកត់សម្គាល់ថាបេសកកម្មដែលបានគ្រោងធ្វើនៅខែកក្កដា គឺមិនអាចទៅរួចទេ ដោយសារតែការរីករាលដាលនៃជំងឺនៅតែបន្តមាន។ ជម្រើសជំនួសតាមប្រព័ន្ធវីដេអូ (Video Conference) ត្រូវបានកំណត់ពេល។ លើសពីនេះទៀត រាល់បេសកកម្មផ្លូវការទាំងអស់ ត្រូវបានហាមឃាត់នៅក្នុងកាលៈទេសៈនេះ។

២. អ្នករាយការណ៍ពិសេស បានប្រមូលព័ត៌មានទាក់ទងនឹងស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាតាមរយៈព័ត៌មានដែលទទួលបានពីឯកសារ និងឯកសារដែលបានបោះពុម្ពផ្សាយដោយរដ្ឋាភិបាល របាយការណ៍ផ្សេងៗដែលចេញដោយទីភ្នាក់ងារទាំងឡាយរបស់អង្គការសហប្រជាជាតិនៅកម្ពុជា និងព័ត៌មានដែលទទួលបានពីអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ សង្គមស៊ីវិល និងភាគីពាក់ព័ន្ធដទៃទៀត។ អ្នករាយការណ៍ពិសេស បានខិតខំប្រមូលព័ត៌មានស៊ីសង្វាក់ និងផ្ទៀងផ្ទាត់ព័ត៌មាន ដោយកត់សម្គាល់ថា បេសកកម្មទៅកាន់ប្រទេសមិនអាចទៅរួច ក្រោមកាលៈទេសៈពិសេស។ យោបល់លម្អិតលើរបាយការណ៍នេះ ព័ត៌មានបច្ចេកទេស និងព័ត៌មានស្ថិតិ ត្រូវបានផ្តល់ដោយរដ្ឋាភិបាលកម្ពុជា។

៣. អ្នករាយការណ៍ពិសេសនៅតែទទួលបានការលើកទឹកចិត្តពីឆន្ទៈរបស់រដ្ឋាភិបាលក្នុងការឆ្លើយតបចំពោះការទំនាក់ទំនងផ្លូវការ ដែលចេញដោយអ្នករាយការណ៍ពិសេស និងអ្នកកាន់អាណត្តិតាមវិស័យនីមួយៗ និងក្នុងការឆ្លើយតបចំពោះរបាយការណ៍ប្រចាំឆ្នាំ ហើយស្វាគមន៍ចំពោះឱកាសទាំងនេះ សម្រាប់បង្កើនកិច្ចសន្ទនា និងការស្វែងយល់កាន់តែស៊ីជម្រៅថែមទៀត។

## II. បរិបទ

៤. ក្នុងកិច្ចពិភាក្សាអន្តរកម្ម នៅខែកញ្ញា ឆ្នាំ២០១៩ រដ្ឋជាច្រើនបានលើកឡើងពីបញ្ហាលំហពលរដ្ឋ និងប្រជាធិបតេយ្យនៅក្នុងប្រទេស។ ដូច្នោះហើយ បញ្ហានេះនឹងត្រូវបានដោះស្រាយមុនគេ។

៥. លំហពលរដ្ឋ និងប្រជាធិបតេយ្យ បានបន្តធ្លាក់ចុះនៅក្នុងប្រទេសកម្ពុជា ដោយកង្វះនៃការផ្លាស់ប្តូរណាមួយឆ្ពោះទៅរកការផ្សះផ្សាផ្នែកនយោបាយ និងការស្តារសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឡើងវិញ។ តាមពិត ប្រទេសកម្ពុជានៅតែជារដ្ឋឯកបក្សដែលគណបក្សកាន់អំណាចគឺជាគណបក្សប្រជាជនកម្ពុជា ដែលកាន់អាសនៈរដ្ឋសភាជាន់ទាបទាំងអស់ និងអាសនៈព្រឹទ្ធសភាស្ទើរតែទាំងអស់។ គណបក្សប្រជាជនកម្ពុជា ក៏កាន់តួនាទីជាសមាជិកក្រុមប្រឹក្សាថ្នាក់មូលដ្ឋានភាគច្រើន តាមសេចក្តីសម្រេចរបស់តុលាការកំពូល ឆ្នាំ២០១៧ ដែលបានរំលាយអតីតគណបក្សប្រឆាំងគឺគណបក្សសង្គ្រោះជាតិ។ បន្ទាប់មកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានបែងចែកអាសនៈ ដែលគណបក្សសង្គ្រោះជាតិបានឈ្នះនៅក្នុងការបោះឆ្នោតឃុំ-សង្កាត់ កាលពីខែមិថុនា ឆ្នាំ២០១៧ ដោយអនុលោមតាមច្បាប់ដែលបានអនុម័តកាលពីពេលថ្មីៗនេះ។[1]

៦. អ្នករាយការណ៍ពិសេស ស្វាគមន៍ការដោះលែង លោក កឹម សុខា អតីតប្រធានគណបក្សសង្គ្រោះជាតិ ពីការឃុំខ្លួនក្នុងផ្ទះតាមព្រឹត្តន័យ នៅខែវិច្ឆិកា ឆ្នាំ២០១៩។ គាត់ត្រូវបានចាប់ខ្លួន និងឃុំខ្លួននៅខែកញ្ញា ឆ្នាំ២០១៧ និងបានឃុំខ្លួនរហូតដល់ ខែកញ្ញា ឆ្នាំ ២០១៨ នៅពេលដែលគាត់ចាប់ផ្តើមរស់នៅស្ថិតក្រោមការឃុំខ្លួនក្នុងផ្ទះតាមព្រឹត្តន័យក្រោមការរឹតត្បិតជាមួយចំនួនដែលកំណត់ដោយតុលាការ។[2] ការជនុំជម្រះក្តីរបស់គាត់បានចាប់ផ្តើមនៅខែមករា ឆ្នាំ២០២០ ក្រោមការចោទប្រកាន់ពីបទក្បត់ និងឃុបឃិតជាមួយរដ្ឋបរទេស ដែលត្រូវជាប់ពន្ធនាគារពី១៥ ឆ្នាំ ទៅ ៣០ ឆ្នាំ ប្រសិនបើត្រូវបានតុលាការកាត់ទោស។ នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០ អ្នករាយការណ៍ពិសេស រួមជាមួយអ្នកកាន់អាណត្តិនីតិវិធីពិសេសផ្សេងទៀត បានសម្តែងការព្រួយបារម្ភលើការជំនុំជម្រះក្តីរបស់គាត់ ដោយកត់សម្គាល់ថា ដំណើរការនីតិវិធីព្រហ្មទណ្ឌទាំងមូល ត្រូវបានរំខានដោយភាពមិនប្រក្រតី។[3] ការជំនុំជម្រះក្តី ត្រូវបានលើកពេលនៅខែមីនា ដោយគ្មានកំណត់ ដោយសារតែនៃការរាតត្បាតនៃជំងឺកូវីដ-១៩។

៧. បន្ថែមលើរបាយការណ៍ផ្ទាល់មាត់របស់លោកស្រីទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្សនាខែកញ្ញា ឆ្នាំ២០១៩ អ្នករាយការណ៍ពិសេស បានបន្តទទួលព័ត៌មានស្តីពីការចាប់ខ្លួន និងការឃុំខ្លួន ការយាយីរំខាន ការបំភិតបំភ័យ និងការរិតត្បិតសកម្មភាពស្របច្បាប់របស់

---

1 សូមមើល A/HRC/39/73បន្ថែម ១។/

2 ២ការិយាល័យ .OHCHR ឧបាស្រ័យលេខ AL KHM 3/2019 ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩។ អាចរកបាននៅលើគេហទំព័រ http://spcommreports.ohchr.org

3 ៣ .គេហទំព័រ www.ohchr.org/EN/NewsEvents/Pages/DisplayNews.aspx?NewsID=25472&LangID=E

មនុស្សមួយចំនួនធំដែលធ្លាប់មាននិន្នាការជាមួយគណបក្សសង្គ្រោះជាតិ។[4] ស្ថានការណ៍កាន់តែតានតឹងខ្លាំងឡើងនៅមុនទិវាឯករាជ្យកម្ពុជា នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ ២០១៩ នៅពេលដែលលោក សម រង្ស៊ី អតីតប្រធានគណបក្សសង្គ្រោះជាតិ បានប្រកាសថាលោកនឹងវិលត្រឡប់មកប្រទេសកម្ពុជាវិញពីការនិរទេសខ្លួន ។

៨- នៅថ្ងៃទី០៨ ខែវិច្ឆិកា អ្នករាយការណ៍ពិសេស បានសម្តែងការព្រួយបារម្ភយ៉ាងខ្លាំងអំពីភាពតានតឹងផ្នែកនយោបាយដែលកើតមាននៅទូទាំងប្រទេស ដោយធ្វើការអំពាវនាវជាសាធារណៈឱ្យរដ្ឋាភិបាលគោរពសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងសិទ្ធិជួបប្រជុំ។ ដោយមានអតីតអ្នកគាំទ្រគណបក្សសង្គ្រោះជាតិជាច្រើននាក់ ត្រូវបានគេរាំងមិនឱ្យធ្វើដំណើរមកប្រទេសកម្ពុជាវិញ ហើយនៅចំពេលដែលមានវោហារសាស្ត្រកាន់តែខ្លាំងឡើងពីសំណាក់លោក សម រង្ស៊ី និងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន អ្នករាយការណ៍ពិសេសបានអំពាវនាវដល់រដ្ឋាភិបាល និងគ្រប់ភាគីទាំងអស់ ឱ្យកាត់បន្ថយការរីកសាយនូវភាពតានតឹង ហើយស្វែងរកកិច្ចពិភាក្សាក្នុងបរិយាកាសមួយប្រកបដោយសន្តិវិធី ដែលអនុញ្ញាតឱ្យមានការបញ្ចេញមតិនយោបាយផ្ទុយគ្នា និងដើម្បីជៀសវាងការរឹតត្បិតបន្ថែមទៀតលើសេរីភាពជាមូលដ្ឋានដែលចាំបាច់ ក្នុងការទទួលបានសិទ្ធិមនុស្សសម្រាប់ទាំងអស់គ្នា។[5] លោក សម រង្ស៊ី មិនបានវិលត្រឡប់មកប្រទេសកម្ពុជាវិញទេ។ គាត់នៅតែស្ថិតក្រោមការផ្តន្ទាទោស និងការចោទប្រកាន់ចំពោះបទល្មើសមួយចំនួន។

៩. អ្នករាយការណ៍ពិសេស បានទទួលព័ត៌មានគួរឱ្យជឿទុកចិត្ត ទាក់ទងនឹងវិធានការមួយចំនួន ប្រឆាំងនឹងគូប្រជែងនយោបាយ និងសមាជិកគណបក្សសង្គ្រោះជាតិ ដែលពាក់ព័ន្ធនឹងការដកហូតឯកសារធ្វើដំណើររបស់ពួកគេ។ នៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៩ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានផ្ញើលិខិតជូនដំណឹងទៅគ្រប់ស្ថានបេសកកម្មការទូតទាំងអស់ ដោយជូនដំណឹងដល់ពួកគេថា លិខិតឆ្លងដែនកម្ពុជាចំនួន ១២ ត្រូវបានប្រកាសទុកជាមោឃៈ ដោយទុកឱ្យអ្នកខ្លះមិនមានឯកសារធ្វើដំណើរ។ បុគ្គលទាំង១២ នាក់ នោះ សុទ្ធតែជាសមាជិកជាន់ខ្ពស់នៃគណបក្សសង្គ្រោះជាតិ។ នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩ លិខិតឆ្លងដែនបន្ថែមរបស់បុគ្គលដទៃផ្សេងទៀត ដែលជាប់ទាក់ទងនឹងគណបក្ស ក៏ត្រូវបានដកហូតវិញដែរ។

១០. នៅមុនខែវិច្ឆិកា ឆ្នាំ២០១៩ អតីតអ្នកជំនួយការ និងសមាជិកគណបក្សសង្គ្រោះជាតិប្រមាណ ៧០ នាក់ ដែលត្រូវបានចាប់ខ្លួនក្នុងរយៈពេលប៉ុន្មានខែមុន និងត្រូវបានគេចាត់ទុកថាជាអ្នកគាំទ្រលោក សម រង្ស៊ី ត្រូវបានដោះលែងពីការឃុំខ្លួន។ ទោះជាយ៉ាងណាក៏ដោយ អ្នករាយការណ៍ពិសេស មានការព្រួយបារម្ភដោយបានដឹងថា បច្ចុប្បន្ននេះ បុគ្គល

[4] ៤ការិយាល័យ .OHCHR ឧបាស្រ័យលេខ JAL KHM 1/2019 ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៩ និងឧបាស្រ័យលេខ JAL KHM 2/2019 ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៩។ អាចរកបាននៅលើគេហទំព័រ http://spcommreports.ohchr.org

[5] ៥ .គេហទំព័រ https://www.ohchr.org/EN/NewsEvents/Pages/DisplayNews.aspx?NewsID=25260&LangID=E

ទាំង ៧៥ នាក់នោះ នៅតែត្រូវបានដោះលែងស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការពោលគឺ មិនត្រូវបានឃុំខ្លួន និងចោទប្រកាន់ឡើយ។ អ្នករាយការណ៍ពិសេស បានគូសបញ្ជាក់ជាថ្មីថា ការត្រួតពិនិត្យតាមផ្លូវតុលាការបែបនេះ ដែលមិនមានកំណត់ពេលវេលាដែលការចោទប្រកាន់អាចនឹងត្រូវបានគាស់ឡើងវិញច្រើនឆ្នាំបន្ទាប់ពីការចាប់ខ្លួនដំបូងគឺមិនស្របទៅនឹងកាតព្វកិច្ចសិទ្ធិមនុស្សរបស់ប្រទេសនេះទេ។[6]

១១. អ្នករាយការណ៍ពិសេស បានបន្តទទួលរបាយការណ៍ជាបន្តបន្ទាប់ អំពីការចាប់ខ្លួន និងការយាយីរំខាន និងការគំរាមកំហែងដល់សមាជិក និងអ្នកគាំទ្រអតីតគណបក្សសង្គ្រោះជាតិ។ ចន្លោះពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៩ ដល់ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ ការិយាល័យ OHCHR បានកត់ត្រាបុគ្គលចំនួន ១៥៦ នាក់ ដែលមានិន្នាការជាមួយគណបក្សនេះ ដែលត្រូវបានចាប់ខ្លួន ដោយមានបុគ្គលចំនួន ១៤ នាក់ ទៀត កំពុងជាប់ឃុំនៅឡើយ។ យោងតាមក្រមព្រហ្មទណ្ឌ បុគ្គលទាំង ១៤ នាក់ នោះ ប្រឈមនឹងការចោទប្រកាន់ រួមមាន បទក្លែងព័ត៌មាន (មាត្រា៤២៥) បទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ (មាត្រា ៤៩៥) និងបទរួមគំនិតក្បត់រដ្ឋាភិបាល (មាត្រា ៤៥៣)។

១២. ក្នុងន័យនេះ អ្នករាយការណ៍ពិសេស រំលឹកពីការទទួលយករបស់រដ្ឋាភិបាលចំពោះអនុសាសន៍ ដែលធ្វើឡើងដោយប្រទេសហ្វាំងឡង់នៅក្នុងអំឡុងពេលពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់ ដែលស្នើឱ្យបញ្ឈប់តាមគ្រប់រូបភាពនូវរាល់ការរំខាន និងការជ្រៀតជ្រែកដោយបំពាន ចំពោះបក្សប្រឆាំងនយោបាយ[7] ហើយលោកស្រីលើកទឹកចិត្តឱ្យមានការប្រសើរឡើងជាបន្ទាន់ឆ្ពោះទៅរកគោលដៅនោះ។ លោកស្រីលើកទឹកចិត្តដល់អាជ្ញាធរឱ្យប្រកាន់ខ្ជាប់នូវបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ និងដោះលែងជនជាប់ឃុំ ប្រសិនបើការចោទប្រកាន់របស់ពួកគេ មិនមានភស្តុតាងបញ្ជាក់។ លោកស្រីបានផ្តល់អនុសាសន៍បន្ថែមទៀតថា ក្រមព្រហ្មទណ្ឌ ត្រូវតែធ្វើវិសោធនកម្មស្របទៅតាមនោះ។

១៣. ព្រឹត្តិការណ៍ឆ្នាំ២០១៩ បង្ហាញពីស្ថិរភាពផុយស្រួយជាក់ស្តែងនៅក្នុងប្រទេស។ អ្នករាយការណ៍ពិសេស បានសម្តែងការព្រួយបារម្ភម្តងហើយម្តងទៀត ចំពោះវោហារសាស្រ្តបែបអរិភាព ដែលមិនអនុញ្ញាតឱ្យមានចលនាហួសពីស្ថានភាពនយោបាយបច្ចុប្បន្ន ដែលអាចបង្កើតឱ្យមានស្មារតីនៃការសន្ទនា និងការផ្សះផ្សា។[8] ទោះបីជាមានសញ្ញាជាបណ្តោះអាសន្ននៃការបើកកិច្ចពិភាក្សារវាងមេដឹកនាំនយោបាយ រួមទាំងសេចក្តីរាយការណ៍ថាមានកិច្ចប្រជុំរវាងលោក កឹម សុខា និងលោកនាយករដ្ឋមន្រ្តី ហ៊ុន សែន នៅខែឧសភា ឆ្នាំ២០២០ ក៏ដោយ ក៏សញ្ញានៃការរីកចម្រើនមានតិចតួចដែរ។

១៤. នៅក្នុងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ប្រទេសកម្ពុជាសំដៅទៅលើក្របខ័ណ្ឌនៃរដ្ឋធម្មនុញ្ញបច្ចុប្បន្ន ទស្សនៈផ្ទុយគ្នាប្រកបដោយការគោរព គឺជាខ្លឹមសារធ្វើឱ្យការយល់ដឹងកាន់តែច្បាស់អំពីសិទ្ធិ និងសេរីភាពនៅក្នុងប្រទេស។ វាជាការចាំបាច់ណាស់ ដែល

6 របាយការណ៍លេខ A/HRC/42/60 កថាខណ្ឌទី៨។
7 របាយការណ៍លេខ A/HRC/41/17 កថាខណ្ឌទី១១០, ១០៩។
8 របាយការណ៍លេខ A/HRC/42/60 កថាខណ្ឌទី72។

កិច្ចពិភាក្សានយោបាយបើកចំហ ត្រូវបានលើកទឹកចិត្តនៅក្នុងប្រទេសកម្ពុជា ប្រកប ដោយលក្ខណៈផ្សះផ្សា ស្ថាបនា ដើម្បីឱ្យរដ្ឋាភិបាលអាចដោះស្រាយកង្វល់បានកាន់តែប្រសើរឡើងថែមទៀត ពីស្ថាប័នតំណាងនៃប្រជាជនកម្ពុជា។

## III. ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា

### ក. លំហពលរដ្ឋ និងសេរីភាពមូលដ្ឋាន

១៥. អ្នករាយការណ៍ពិសេសបន្តទទួលរបាយការណ៍ស្តីពីការរឹតត្បិតលើសកម្មភាពនិងការរស់នៅរបស់តួអង្គសង្គមស៊ីវិល។ ជាពិសេស លោកស្រីបានទទួលរបាយការណ៍ស្តីពីការរឹតត្បិតដែលផ្ទុយនឹងគោលការណ៍ណែនាំស្តីពីការអនុវត្តច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី។ គួរកត់សម្គាល់ថាការកង្វល់ទាំងនេះមិនទាក់ទងនឹងការរឹតត្បិតនាពេលបច្ចុប្បន្នលើការប្រមូលផ្តុំធំៗ ដែលជាវិធានការមួយសំដៅរក្សាសុខភាពសាធារណៈ ដែលនឹងពិភាក្សានៅផ្នែកខាងក្រោម។

១៦. អ្នករាយការណ៍ពិសេសរំលឹករដ្ឋាភិបាលថា មានការសន្មតជាមុនដោយច្បាប់ជាប្រយោជន៍ដល់ការទទួលបានសេរីភាពក្នុងការជួបជុំ និងសេរីភាពខាងសមាគម។ នេះឆ្លុះបញ្ចាំងពីកាតព្វកិច្ចរបស់កម្ពុជាទាក់ទងនឹងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

១៧. អ្នករាយការណ៍ពិសេសនៅតែមានកង្វល់ចំពោះបទប្បញ្ញត្តិមួយចំនួននៃក្រមព្រហ្មទណ្ឌ និងបទប្បញ្ញត្តិផ្សេងទៀត ដែលត្រូវបានគេប្រើ ដើម្បីចោទប្រកាន់អ្នកដែលបញ្ចេញមតិ រួមទាំងតាមអនឡាញ[9] លោកស្រីស្វាគមន៍ចំពោះការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល ក្នុងអំឡុងពេលពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់ ក្នុងគោលដៅធ្វើឱ្យច្បាប់ បទបញ្ញត្តិ និងគោលនយោបាយស្តីពីសេរីភាពក្នុងការបញ្ចេញមតិ សេរីភាពខាងសមាគម និងសេរីភាពក្នុងការជួបប្រជុំគ្នាជាសាធារណៈ ស្របតាមអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដូចដែលប្រទេសដាណឺម៉ាកបានផ្តល់ជាអនុសាសន៍[10] និងដើម្បីធានាសេរីភាពក្នុងការបញ្ចេញមតិសម្រាប់ប្រជាជនកម្ពុជា និងអ្នកសារព័ត៌មានទាំងអស់ រួមទាំងនៅលើប្រព័ន្ធអ៊ិនធឺណិត តាមរយៈការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញចុងក្រោយបំផុត និងសេចក្តីណែនាំអន្តរក្រសួង ចុះខែឧសភា ឆ្នាំ២០១៨ ដែលអនុញ្ញាតឱ្យមានការឃ្លបមើលខ្លឹមសារអ៊ិនធឺណិត ដូចដែលប្រទេសបារាំងបានផ្តល់ជាអនុសាសន៍។[11]

១៨. អ្នករាយការណ៍ពិសេស ក៏ត្រូវបានលើកទឹកចិត្តផងដែរថា រដ្ឋាភិបាលបានគាំទ្រអនុសាសន៍ដែលបានផ្តល់ដោយប្រទេសអាហ្សង់ទីន និងប្រទេសឈីលីក្នុងជុំ (វដ្ត)ទី ៣ នៃការពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់ ដោយយល់ព្រមអនុម័តវិធានការចាំបាច់មួយចំនួន ដើម្បីការពារសិទ្ធិអ្នកការពារសិទ្ធិមនុស្ស សហជីព និងអ្នកសារ

[9] របាយការណ៍លេខ A/HRC/36/61 កថាខណ្ឌទី៤៧ និងទី៦៩ ។(គ)

[10] របាយការណ៍លេខ A/HRC/41/17 កថាខណ្ឌទី១១០,១០៥។

[11] ឯកសារដដែល កថាខណ្ឌទី១១០,៨១ ។ សូមមើលផងដែរ កថាខណ្ឌទី១១០,៩៤ និងទី១១០,៩៦។

ព័ត៌មាន [12] ស៊ើបអង្កេត និងដាក់ទោសទណ្ឌអ្នកដែលទទួលខុសត្រូវចំពោះការគំរាមកំហែង និងអំពើហឹង្សាលើអ្នកការពារសិទ្ធិមនុស្ស និងក្រុមគ្រួសាររបស់ពួកគេ។[13] លោកស្រីសង្ឃឹមថានឹងមានការអនុវត្តនូវការផ្លាស់ប្តូរច្បាប់ចាំបាច់ ដែលនឹងការពារអ្នកការពារសិទ្ធិមនុស្សសហជីព និងអ្នកសារព័ត៌មានទាំងអស់ ហើយនិងធានាការគំរាមកំហែង និងការយាយីដល់ពួកគេនិងក្រុមគ្រួសាររបស់ពួកគេត្រូវបានស៊ើបអង្កេតភ្លាមៗ ហើយជនល្មើសត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។

១៩. ទោះយ៉ាងណាក៏ដោយ មានមនុស្សមួយចំនួនដែលត្រូវបានគេរាយការណ៍ថាបានបង្ហាញទស្សនៈអំពីជំងឺកូវីដ-១៩ ត្រូវបានអាជ្ញាធរចាប់ខ្លួន និងឃុំខ្លួន។ យោងតាមក្រមព្រហ្មទណ្ឌ បទចោទលើពួកគេ រួមមាន ការផ្សព្វផ្សាយព័ត៌មានមិនពិត (មាត្រា ៤២៥) ការញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ (មាត្រា ៤៩៥) និងការឃុបឃិតប្រឆាំងនឹងរដ្ឋាភិបាល (មាត្រា ៤៥៣) ។ ការអនុវត្តបែបនេះ បាននាំឱ្យមានការត្រួតពិនិត្យដោយខ្លួនឯងបន្ថែមទៀតក្នុងចំណោមអ្នកសារព័ត៌មាន ដែលកម្រិតសិទ្ធិរបស់សាធារណៈជនក្នុងការទទួលបានព័ត៌មានទាន់ពេលវេលា និងអាចទុកចិត្តបាននៅពេលចាំបាច់។

២០. នៅចន្លោះខែមេសា និងខែឧសភា ឆ្នាំ២០២០ អ្នករាយការណ៍ពិសេស ត្រូវបានគេប្រាប់ឱ្យដឹងថា រដ្ឋាភិបាលបានដកហូតអាជ្ញាប័ណ្ណប្រព័ន្ធផ្សព្វផ្សាយចំនួន ៣ គឺទូរទស្សន៍ហ្វេសប៊ុក TVFB និងស៊ីខេវីធីវី និងស្ថានីយ៍វិទ្យុរិទ្ធិសែន ដោយអះអាងថាបណ្តាញផ្សព្វផ្សាយទាំងនេះបាននិងកំពុងផ្សព្វផ្សាយព័ត៌មានបំផ្លើស ហើយថាមានខ្លឹមសារញុះញង់ឱ្យមានអំពើហឹង្សា ញុះញង់ឱ្យមានការរើសអើង និងការបង្កឱ្យមានអសន្តិសុខសង្គម និងភាពវឹកវរ។ យោបល់ដែលទទួលបានពីរដ្ឋាភិបាល ផ្តល់ព័ត៌មានបច្ចេកទេស និងស្ថិតិបន្ថែមស្តីពីប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា។

២១. នៅខែកក្កដា ឆ្នាំ២០១៩ នីតិវិធីពិសេសមួយចំនួន បានចេញលិខិតចោទប្រកាសចូលរួមគ្នាមួយ ទាក់ទងនឹងការចាប់ខ្លួន និងការកាត់ទោសលោក គង់ រ៉ៃយ៉ា និងលោកសួង នាគព័ន្ធ។ អ្នកទាំងពីរត្រូវបានចាប់ខ្លួនពាក់ព័ន្ធនឹងសកម្មភាពរំលឹកខួបឆ្នាំទីបី នៃឃាតកម្មលើលោក កែម ឡី ខែកក្កដា ឆ្នាំ២០១៦ ។[14]

២២. បទល្មើសដែលត្រូវបានចោទប្រកាន់លើលោក រ៉ៃយ៉ា យោងតាមក្រមព្រហ្មទណ្ឌនៃប្រទេសកម្ពុជាគឺជាការញុះញង់ឱ្យប្រព្រឹត្តបទល្មើស (មាត្រា ៤៩៤ និង ៤៩៥) ដែលកើតចេញពីការផ្សព្វផ្សាយអាវយឺតដែលមានបោះពុម្ពផ្សាយ ដែលមានសរសេរអក្សរ និងរូបភាពលោក កែម ឡី។ រដ្ឋាភិបាលបានបញ្ជាក់ថា សកម្មភាពនេះមានគោលបំណងញុះញង់ឱ្យមានភាពវឹកវរក្នុងសង្គម និងការស្អប់ខ្ពើម។[15] លោក រ៉ៃយ៉ា ត្រូវបានឃុំខ្លួនចាប់ពីខែកក្កដា

12 ឯកសារដដែល កថាខណ្ឌទី១១០,១១៦។

13 ឯកសារដដែល កថាខណ្ឌទី១១០, ១១៥។

14 ការិយាល័យOHCHR ឧបាស្រ័យលេខ AL KHM 4/2016 ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៦ ។ អាចរកបាននៅលើគេហទំព័រ http://spcommreports.ohchr.org។

15 ១៥ .រដ្ឋាភិបាលកម្ពុជា ឧបាស្រ័យលេខ 2019/09/328 ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ ឆ្លើយតបនឹងឧបាស្រ័យលេខ KHM 4/2019 របស់ការិយាល័យOHCHR ។ អាចរកបាននៅលើគេហទំព័រ http://spcommreports.ohchr.org

រហូតដល់ ខែវិច្ឆិកា នៅពេលដែលលោកត្រូវបានដោះលែងឱ្យនៅក្រៅឃុំ រួមជាមួយបុគ្គលមួយចំនួនទៀត ដែលត្រូវបានឃុំខ្លួនក្នុងរយៈពេលប៉ុន្មានខែមុននេះ។ នៅខែមិថុនា ឆ្នាំ២០២០ គាត់ត្រូវបានជំនុំជម្រះ និងផ្តន្ទាទោសឱ្យជាប់ពន្ធនាគាររយៈពេល ២ ឆ្នាំ។

២៣. លោក នាគ ព័ន្ធ បានកំពុងព្យាយាមធ្វើពិធីរំលឹកខួបមរណភាពរបស់លោក កែម ឡី នៅទីកន្លែងដែលលោកត្រូវបានគេបាញ់សម្លាប់។ យោងតាមការបំភ្លឺរបស់រដ្ឋាភិបាល លោក នាគ ព័ន្ធ ត្រូវបានចាប់ខ្លួននៅពេលដែលលោកនិយាយថា អាជ្ញាធរគួរតែស្វែងរកឃាតករដែលសម្លាប់ លោក កែម ឡី។ ក្នុងនាមជាបុគ្គលម្នាក់ត្រូវបានផ្តន្ទាទោសរួចហើយទាក់ទងទៅនឹងឃាតកម្មនេះ រដ្ឋាភិបាលបានពន្យល់ថាសេចក្តីថ្លែងការណ៍របស់គាត់អាចសាធារណជនភាន់ច្រឡំ និងធ្វើឱ្យខូចទំនុកចិត្តលើសេចក្តីសម្រេចរបស់តុលាការ ដែលញុះញង់បង្កឱ្យមានភាពវឹកវរក្នុងសង្គម។[16]

២៤. រដ្ឋាភិបាលបានបំភ្លឺជាសាធារណៈអំពីការដែលខ្លួនយល់អំពីស្ថានភាព និងកាលៈទេសៈដោយផ្អែកលើច្បាប់ជាតិដើម្បីកម្រិតកំណត់សេរីភាពក្នុងការបញ្ចេញមតិ។[17] រដ្ឋាភិបាលបានបញ្ជាក់ថាការនិយាយស្តីបែបនយោបាយ និងការធ្វើអត្ថាធិប្បាយលើកិច្ចការសាធារណៈដោយការជេរប្រមាថ ការញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ នាំឱ្យមានការបះបោរប្រឆាំងនឹងរដ្ឋាភិបាលដែលបានជាប់ឆ្នោតតាមបែបប្រជាធិបតេយ្យ ហើយការផ្សព្វផ្សាយព័ត៌មានក្លែងក្លាយ និងការផ្សាយព័ត៌មានមិនពិតដោយចេតនា ឬអចេតនា មិនចាត់ថាជាការអនុវត្តសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងជាសំដីស្របច្បាប់ឡើយ។ ទង្វើនេះ អាចធ្វើឱ្យអន្តរាយដល់នីតិរដ្ឋ សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យក្នុងពេលតែមួយនិងសម្រាប់ទាំងអស់គ្នា។[18] ជាការពិតណាស់ ដូចដែលរដ្ឋាភិបាលបានកត់សម្គាល់ សេរីភាពក្នុងការបញ្ចេញមតិ អាចត្រូវបានកម្រិតកំណត់ដើម្បីការពារសុខភាព និងសណ្តាប់ធ្នាប់សាធារណៈ។ ទោះជាយ៉ាងណាក៏ដោយ សុន្ទរកថានយោបាយ និងការធ្វើអត្ថាធិប្បាយលើកិច្ចការសាធារណៈ សូម្បីតែការរិះគន់ តែប៉ុណ្ណឹង មិនគ្រប់គ្រាន់អាចចាត់ថាជាការគំរាមកំហែងដល់សុខភាពសាធារណៈ ឬសណ្តាប់ធ្នាប់សាធារណៈឡើយ។ ការរិះគន់រដ្ឋាភិបាល និងការដាក់ឱ្យរដ្ឋាភិបាលទទួលខុសត្រូវ គឺជាផ្នែកមួយដ៏សំខាន់នៃសង្គមប្រជាធិបតេយ្យ។ ការដែលគ្មានគណបក្សប្រឆាំងផ្នែកនយោបាយ តួនាទីរបស់សង្គមស៊ីវិល និងសាធារណជន ក្នុងការដាក់ឱ្យរដ្ឋាភិបាលទទួលខុសត្រូវ គឺរឹតតែសំខាន់ទៅទៀត។ ការរិះគន់ក្នុងន័យស្ថាបនា និងការបង្កើតដំណោះស្រាយវិជ្ជមានរួមគ្នាចំពោះបញ្ហាប្រឈមដែលបានកំណត់គឺមានសារៈសំខាន់។

[16] ឯកសារដដែល

[17] សេចក្តីប្រកាសព័ត៌មាន ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២០ របស់ស្ថានបេសកម្មអចិន្ត្រៃយ៍កម្ពុជា នៅហ្សឺណែវ ដូចបានចុះផ្សាយឡើងវិញនៅក្នុងសារព័ត៌មាន Fresh News Asia «ស្ថានបេសកកម្មអចិន្ត្រៃយ៍កម្ពុជានៅហ្សឺណែវ៖ «ការផ្សព្វផ្សាយព័ត៌មានក្លែងក្លាយ នឹងការក្លែងព័ត៌មាន ពុំមានតម្លៃស្មើនឹងសេរីភាពបញ្ចេញមតិ នឹងការនិយាយស្របច្បាប់ឡើយ» ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២០ ។ សូមមើលផងដែរ មតិយោបល់ដែលទទួលបានពីរដ្ឋាភិបាលទាក់ទងនឹងកថាខណ្ឌទី២១។ ២៣–

[18] សេចក្តីប្រកាសព័ត៌មាន ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២០ របស់ស្ថានបេសកកម្មអចិន្ត្រៃយ៍កម្ពុជា នៅហ្សឺណែវ កថាខណ្ឌទី៤ ។

២៥. ទាមទារឱ្យយកចិត្តទុកដាក់ខ្ពស់ចំពោះបទប្បញ្ញត្តិមាតិកាតាមអ៊ិនធឺណិត ដូចដែលអ្នករាយការណ៍ពិសេសស្តីពីការលើកកម្ពស់ និងការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងយោបល់ បានគូសបញ្ជាក់ជាថ្មី។[19] ច្បាប់ជាច្រើន រួមទាំងច្បាប់ព្រហ្មទណ្ឌ ដែលនៅតែបន្តដាក់ការកម្រិតកំណត់លើសេរីភាពក្នុងការបញ្ចេញមតិ គួរតែពិនិត្យឡើងវិញ ជាពិសេសនៅពេលដែលការឃុំខ្លួនបណ្តោះអាសន្ននៅតែបន្តមានរយៈពេលវែង ជាជាងក្នុងករណីពិសេសដែលបានកត់សម្គាល់នៅក្នុងក្រមព្រហ្មទណ្ឌ។ លើសពីនេះទៀត នៅពេលចាប់ខ្លួនមនុស្ស ក្នុងពេលមានជំងឺរាតត្បាតនាពេលបច្ចុប្បន្ននេះ រដ្ឋាភិបាលគួរតែយកចិត្តទុកដាក់ចំពោះការណែនាំដែលបានផ្តល់ជូនដោយក្រុមការងារស្តីពីការឃុំខ្លួនដោយបំពានតាមវិធានលេខ ១១ របស់ខ្លួន ស្តីពីការការពារការដកហូតសិទ្ធិសេរីភាពដោយបំពានក្នុងបរិបទនៃភាពអាសន្នផ្នែកសុខភាពសាធារណៈ។[20]

២៦. អ្នករាយការណ៍ពិសេសមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការកើនឡើងនាពេលថ្មីៗនេះ ក្នុងករណីមានការយាយីរំខាន និងការដាក់ជាបទព្រហ្មទណ្ឌ ចំពោះសកម្មជនបរិស្ថាន និងសកម្មជនដីធ្លី។ នៅក្នុងខែមេសា ឆ្នាំ២០២០ ក្រសួងបរិស្ថាន បានព្រមានថាខ្លួននឹងចាត់វិធានការតាមផ្លូវច្បាប់ ប្រឆាំងនឹងអង្គការមិនមែនរដ្ឋាភិបាលទាំងឡាយណាដែលបានប្រើប្រាស់សកម្មភាពបរិស្ថាន ជាការបិទបាំងសំដៅវាយប្រហាររដ្ឋាភិបាល។ [21] ឧទាហរណ៍មួយចំនួន ជាករណីថ្មី របស់លោក គ្រឹង តុលា សកម្មជនការពារព្រៃឈើខេត្តមណ្ឌលគិរី ដែលត្រូវបានតុលាការខេត្តកោះហៅជាញឹកញាប់ ពីបទចោទប្រកាន់រួមមានបទបរិហារកេរ្តិ៍ ការជេរប្រមាថជាសាធារណៈ និងការញុះញង់[22] និងការចាប់ខ្លួននិងឃុំខ្លួនកាលពីខែមិថុនា ឆ្នាំ២០២០ នូវសកម្មជនយុវជនចំនួន១៨ នាក់ ពីអង្គការបរិស្ថានមាតាធម្មជាតិ។

២៧. អ្នករាយការណ៍ពិសេសស្វាគមន៍សេចក្តីសម្រេចរបស់តុលាការកំពូល នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ ពាក់ព័ន្ធនឹងករណីរបស់សកម្មជនបរិស្ថានចំនួន២ រូបដែលក្នុងនោះតុលាការបានបង្គាប់ឱ្យធ្វើការជំនុំជម្រះឡើងវិញ ដោយបញ្ជូនសំណុំរឿងនេះទៅសាលាឧទ្ធរណ៍ ដោយសារគ្មានភស្តុតាងគ្រប់គ្រាន់ដើម្បីគាំទ្រការចោទប្រកាន់ព្រហ្មទណ្ឌ។ អ្នកទាំងពីរត្រូវបានសាលាឧទ្ធរណ៍ផ្តន្ទាទោសពីបទរំលោភលើសិទ្ធិឯកជន និងប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋក្រោមក្រមព្រហ្មទណ្ឌ។ ពួកគេត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលមួយឆ្នាំ និងពិន័យជាប្រាក់ចំនួន ១ លាន រៀល (ប្រមាណជា ២៤៣ ដុល្លារ) ។ អ្នក

19 របាយការណ៍លេខ A/HRC/38/35។ សម្រាប់របាយការណ៍សង្ខេប សូមចូលទៅកាន់គេហទំព័រ www.ohchr.org/Documents/Issues/Expression/Factsheet_2.pdf

20 គេហទំព័រ www.ohchr.org/Documents/Issues/Detention/DeliberationNo11.pdf (កថាខណ្ឌទី២២។(

21 ២១ .លោក វ៉ន ដារ៉ាគ្រាន់តែជា " សកម្មភាពព្រៃឈើ" ការបិទបាំងមួយប៉ុណ្ណោះ កាសែតភ្នំពេញប៉ុស្ដិ៍ "ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២០។

22 ក្នុងខែឧសភា ឆ្នាំ២០២០ តែមួយគត់ លោក តុលា បានទទួលដីកាកោះចំនួនបួនផ្សេងគ្នាឱ្យបង្ហាញខ្លួននៅសាលាដំបូងខេត្ត។

រាយការណ៍ពិសេសបានលើកឡើងពីការព្រួយបារម្ភអំពីលក្ខខណ្ឌតម្រូវខាងភស្តុតាងនៅក្នុងច្បាប់ និងបទដ្ឋានភស្តុតាងដែលត្រូវបានប្រើនៅក្នុងតុលាការកម្ពុជា។[23]

២៨. អ្នករាយការណ៍ពិសេស លើកទឹកចិត្តរដ្ឋាភិបាលឱ្យធ្វើការកាន់តែជិតស្និទ្ធជាមួយអង្គការសង្គមស៊ីវិល ដោយមិនគិតពីទស្សនៈនិងវិស័យប្រតិបត្តិការរបស់ពួកគេឡើយ។ ការធ្វើការកាន់តែជិតស្និទ្ធជាមួយអង្គការសង្គមស៊ីវិល ជួយឱ្យមានការយល់ដឹងកាន់តែស៊ីជម្រៅថែមទៀត អំពីបញ្ហាសិទ្ធិមនុស្ស លើកកំពស់គណនេយ្យភាពរបស់រដ្ឋាភិបាល និងដោះស្រាយភាពខុសគ្នានៅជាប់ចាក់ស្រេះ។

២៩. កិច្ចខិតខំប្រឹងប្រែងដំបូង ដែលធ្វើឡើងដោយក្រសួងមហាផ្ទៃ[24] ដើម្បីបញ្ឈប់ការអនុវត្តសេចក្តីណែនាំខែតុលា ឆ្នាំ២០១៧ របស់ខ្លួន ដែលតម្រូវឱ្យអង្គការសង្គមស៊ីវិលផ្តល់ការជូនដំណឹងរយៈពេល ៣ ថ្ងៃ មុនសកម្មភាពដែលបានគ្រោងទុក អាចត្រូវបានអភិវឌ្ឍបន្ថែមទៀតក្រោមក្របខ័ណ្ឌច្បាប់ និងគោលនយោបាយសមស្រប។ ផែនការបែបនេះក៏គួរតែធានាបាននូវភាពប្រក្រតី និងការទទួលយកភាសាសិទ្ធិមនុស្សនៅក្នុងរដ្ឋាភិបាល និងសង្គម។ ដូចដែលបានកត់សម្គាល់ក្នុងឆ្នាំ២០១៩ ការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល ត្រូវតែជាការពិគ្រោះយោបល់ដ៏សំខាន់ ដែលផ្តល់ព័ត៌មាន និងមានឥទ្ធិពលលើការធ្វើច្បាប់ គោលនយោបាយ និងការអនុវត្ត។[25] វាមានសារៈសំខាន់ណាស់ ដែលដំណើរការទាំងនេះ មានបរិយាបន្ន ហើយថាសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ដែលមានបំណងចង់ចូលរួម អាចចូលរួមបាន។ មានតែធ្វើដូច្នេះទេ ទើបកម្ពុជានឹងចាប់ផ្តើមកសាងសង្គមមួយមានបរិយាបន្នច្រើនថែមទៀត នឹងស្តាប់សំលេងទាំងអស់នៅក្នុងការពិគ្រោះយោបល់ និងការចូលរួមប្រកបដោយអត្ថន័យ។[26]

៣០. អ្នករាយការណ៍ពិសេសទទួលស្គាល់ឆន្ទៈរបស់ប្រទេសកម្ពុជា ក្នុងការធានាឱ្យមានលំហរពលរដ្ឋដោយសេរី ដូចដែលបានបង្ហាញដោយការគាំទ្ររបស់ខ្លួនចំពោះអនុសាសន៍ពាក់ព័ន្ធក្នុងអំឡុងពេលពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់។ [27] កម្ពុជាគួរតែបន្តអន្តរកម្មវិជ្ជមានរបស់ខ្លួនជាមួយអង្គការសង្គមស៊ីវិលនានា។ ការពិគ្រោះយោបល់ទាំងនេះ គួរតែមានជាដំកំភួន និងជួយកសាងសង្គមដែលមានបរិយាបន្នច្រើនថែមទៀត តាមរយៈការចូលរួមប្រកបដោយអត្ថន័យ។ ក្រុមសិទ្ធិមនុស្ស មិនអាចត្រូវបានចាត់ទុកថាទីទៃពីគ្នាចំពោះការខិតខំរបស់ពួកគេ ដើម្បីផ្តល់យោបល់ ផ្សព្វផ្សាយ និងផ្តល់ព័ត៌មានការដាក់ឱ្យរដ្ឋាភិបាលទទួលខុសត្រូវលើបញ្ហាសិទ្ធិមនុស្ស។

---

[23] របាយការណ៍លេខ A/HRC/39/73 កថាខណ្ឌទី៨០។

[24] របាយការណ៍លេខ A/HRC/42/60 កថាខណ្ឌទី៥១ ។

[25] ឯកសារដដែល កថាខណ្ឌទី៥២។

[26] ឯកសារដដែល ។

[27] របាយការណ៍លេខ A/HRC/41/17 កថាខណ្ឌទី១១០.១០២ និងទី១១០.១១០ ។

## ខ. សិទ្ធិដីធ្លី និងសិទ្ធិលំនៅដ្ឋាន

៣១. អ្នករាយការណ៍ពិសេសនៅតែមានកង្វល់អំពីសេចក្ដីរាយការណ៍ថាមានការបណ្ដេញចេញដោយបំពាន និងបញ្ហាមួយចំនួនដែលជាប់ទាក់ទងនឹងសិទ្ធិដីធ្លី ដែលនៅតែមិនមានការដោះស្រាយ ទោះបីជាអ្នកស្រីបានអំពាវនាវម្ដងហើយម្ដងទៀត និងបានសុំចូលខ្លួនជួយផ្ដល់ការគាំទ្រក្ដី។ អ្នករាយការណ៍ពិសេស លើកទឹកចិត្តឱ្យរដ្ឋាភិបាលពិនិត្យឡើងវិញនូវយន្តការច្បាប់ និងនីតិវិធីដែលមានស្រាប់ទាក់ទងនឹងការបែងចែក ការលក់ និងការប្រើប្រាស់ដី ហើយប្រសិនជាសមស្រប ដើម្បីណែនាំច្បាប់ និងគោលនយោបាយ ដើម្បីដោះស្រាយវិសមភាព ការបាត់បង់ឱកាស និងភាពក្រីក្រ។ នៅក្នុងអំឡុងពេលបច្ចុប្បន្ននេះដែលមានជំងឺរាតត្បាត អ្នកស្រីសូមទាក់ទាញការយកចិត្តទុកដាក់របស់រដ្ឋាភិបាលចំពោះសេចក្ដីថ្លែងការណ៍របស់អ្នករាយការណ៍ពិសេសស្ដីពីសិទ្ធិមានលំនៅដ្ឋានសមរម្យ ក្នុងខែមីនា ឆ្នាំ២០២០ ដែលបញ្ជាក់ថា យ៉ាងហោចណាស់ដើម្បីធានាការការពារអ្នកដែលរស់នៅក្នុងភាពគ្មានផ្ទះសម្បែង ឬលំនៅដ្ឋានដែលមានគុណភាពមិនគ្រប់ជ្រុងជ្រោយ រដ្ឋត្រូវតែបញ្ឈប់រាល់ការបណ្ដេញចេញទាំងអស់។ សេចក្ដីថ្លែងការណ៍ក៏បានបង្ហាញផងដែរថា តាមរយៈការធានាបាននូវការទទួលបានលំនៅដ្ឋានប្រកបដោយសុវត្ថិភាព ដែលមានអនាម័យគ្រប់គ្រាន់ រដ្ឋមិនត្រឹមតែត្រូវការពារអាយុជីវិតរបស់អ្នកដែលគ្មានផ្ទះសម្បែង ឬអ្នកដែលរស់នៅកន្លែងតាំងទីលំនៅមិនរៀបរយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវជួយការពារប្រជាជនទូទាំងពិភពលោកផងដែរ តាមរយៈការកាត់បន្ថយការរីករាលដាលនៃជំងឺកូវីដ-១៩។[28]

៣២. អ្នករាយការណ៍ពិសេសកត់សម្គាល់ថា សហគមន៍ជនជាតិដើមភាគតិចចំនួន ៣០ បបច្ចុប្បន្ននេះ បានទទួលប័ណ្ណកម្មសិទ្ធិដីសមូហភាពពីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់។ សរុបចំនួន១៣១ នាក់ បានទទួលលិខិតទទួលស្គាល់ឋានៈរបស់ពួកគេពីក្រសួងមហាផ្ទៃ ហើយសហគមន៍ចំនួន១៥១ បានទទួលលិខិតទទួលស្គាល់អត្តសញ្ញាណរបស់ពួកគេជាជនជាតិដើមភាគតិច ពីក្រសួងអភិវឌ្ឍន៍ជនបទ។

៣៣. ទោះបីជាមានវឌ្ឍនភាពទាំងនេះក្ដី និងការប្ដេជ្ញាចិត្តពីមុន ដើម្បីធ្វើឱ្យសាមញ្ញដល់ដំណើរការផ្ដល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពសម្រាប់ជនជាតិដើមភាគតិច ដោយទទួលយកអនុសាសន៍ [29] ពាក់ព័ន្ធនៃការពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់ឆ្នាំ ២០១៩ ដំណើរការនៃការចេញប័ណ្ណកម្មសិទ្ធិដីធ្លី នៅតែមានភាពស្មុគស្មាញ និងយឺតយ៉ាវក្នុងការទទួលបានការការពារគត់ហ្មត់សម្រាប់ជនជាតិដើមភាគតិច ដែលធ្វើឱ្យអន្តរាយជាពិសេសដល់បញ្ញត្តិធានាការពារផ្នែកនីតិវិធី ដែលមានចែងក្នុងច្បាប់ជាតិបច្ចុប្បន្ន។ អ្នករាយការណ៍ពិសេស ទទួលបានព័ត៌មានដែលអាចជឿទុកចិត្តបានថា សហគមន៍មូលដ្ឋាន និងសហគមន៍ជនជាតិដើមភាគតិចជាច្រើន ដែលរស់នៅក្នុង ឬក្បែរតំបន់ការពារបរិស្ថាន ត្រូវបានគេរឹតត្បិតសិទ្ធិចូលទៅកាន់ដីប្រពៃណីរបស់ពួកគេ។ ទោះបីមានបទប្បញ្ញត្តិនៅ

28 គេហទំព័រ www.ohchr.org/en/NewsEvents/Pages/DisplayNews.aspx?NewsID=25727&LangID=E

29 របាយការណ៍លេខ A/HRC/41/17 កថាខណ្ឌទី១១០.២០–១១០.២៣ និងទី១១០.១៣០ ។

ក្នុងច្បាប់តំបន់ការពារ ឆ្នាំ២០០៨ អនុញ្ញាតឱ្យចូលក្តី ក៏អាជ្ញាធរបរិស្ថានក្នុងតំបន់តែងតែបដិសេធសិទ្ធិទាំងនោះ ពេលខ្លះនាំឱ្យមានភាពតានតឹង និងមានបណ្តឹងព្រហ្មទណ្ឌប្រឆាំងនឹងមេដឹកនាំ ឬសកម្មជនសហគមន៍ទៀតផង។

៣៤. នៅថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១៩ ក្រសួងអភិវឌ្ឍន៍ជនបទ បានចេញសារាចរលេខ ១៤៨/១៩ បង្កើតក្រុមការងារបច្ចេកទេសស្តីពីការអភិរក្ស និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច។ ក្រុមការងារនេះ មានអ្នកតំណាងមកពីក្រសួងផ្សេងៗ ជាង២០ នាក់ តំណាងអាជ្ញាធរមូលដ្ឋានមកពីខេត្តចំនួន១៥ អង្គការសង្គមស៊ីវិលចំនួន៤ និងទីភ្នាក់ងារអង្គការសហប្រជាជាតិចំនួន២ ។ អ្នករាយការណ៍ពិសេស មានការស្រងាកចិត្តដោយកត់សម្គាល់ថាក្រសួងអភិវឌ្ឍន៍ជនបទ បានរំលាយក្រុមការងារនេះ កាលពីថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០ ដោយមិនបានផ្តល់មូលហេតុផ្លូវការណាមួយឡើយ។

## គ. ការមិនទុកនរណាម្នាក់ចោល

៣៥. ក្នុងរយៈពេល៥ ឆ្នាំ កន្លងមកនេះ អ្នករាយការណ៍ពិសេស បានសង្កត់ធ្ងន់លើរបាយការណ៍របស់អ្នកស្រីស្តីពីស្ថានភាពរបស់បុគ្គល និងក្រុមជាច្រើន នៅកម្ពុជាដែលបាត់បង់ឱកាស ជាពិសេស ដែលងាយរងគ្រោះ និងដែលមានហានិភ័យត្រូវគេទុកចោល។ អ្នកស្រីបានផ្តល់អនុសាសន៍មួយចំនួន អំពាវនាវឱ្យគោរពឱ្យបានពេញលេញនូវសិទ្ធិនិងសេរីភាពរបស់មនុស្សគ្រប់រូបនៅកម្ពុជា ដែលភាគច្រើនមិនទាន់បានអនុវត្តនៅឡើយ។ ជាពិសេស អ្នកស្រីបានលើកឡើងពីលទ្ធភាពក្នុងការអនុម័តច្បាប់មួយដែលមានលក្ខណៈទូលំទូលាយមិនរើសអើង។[30]

៣៦. នៅត្រីមាសទី៤ ឆ្នាំ២០១៩ គណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីបានផ្តល់អនុសាសន៍ថា រដ្ឋគួរតែធានាថា ច្បាប់ជាតិរបស់ខ្លួន រួមបញ្ចូលទាំងនិយមន័យនៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ការគ្របដណ្តប់ការរើសអើងដោយផ្ទាល់ និងដោយប្រយោលនៅក្នុងវិស័យសាធារណៈ និងវិស័យឯកជន រួមទាំងទម្រង់អន្តរវិស័យនៃការរើសអើង ស្របតាមមាត្រា១ នៃអនុសញ្ញានេះ ដូចដែលបានទទួលយកដោយរដ្ឋភាគីបន្ទាប់ពីការពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់លើកទី៣។[31] បន្ទាប់ពីការសន្ទនាក្នុងន័យស្ថាបនារបស់ពួកគេមួយខែក្រោយមក គណៈកម្មាធិការលុបបំបាត់ការរើសអើងពូជសាសន៍ បានផ្តល់អនុសាសន៍ថា រដ្ឋភាគីត្រូវអនុម័តឱ្យបានឆាប់រហ័សនូវច្បាប់ទូលំទូលាយមួយ ដែលកំណត់ និងហាមឃាត់ការរើសអើងជាតិសាសន៍ដោយផ្ទាល់ និងដោយប្រយោល លើហេតុផលដែលបានហាមឃាត់ទាំងអស់ ស្របតាមមាត្រា១ នៃអនុសញ្ញានេះ និងបង្កើតផែនការសកម្មភាពជាតិមួយ ប្រឆាំងនឹងការរើសអើងពូជសាសន៍។[32]

30 របាយការណ៍លេខ ក/HRC/42/60 កថាខណ្ឌទី៧៤ (i )។
31 របាយការណ៍លេខ CEDAW/C/KHM/CO/6 កថាខណ្ឌទី៩ (ក) ។ សូមមើលផងដែរ របាយការណ៍លេខ A/HRC/41/17/Add.1 កថាខណ្ឌទី២ ។
32 របាយការណ៍លេខ CERD/C/KHM/CO/14-17 កថាខណ្ឌទី១២ ។

៣៧. អ្នករាយការណ៍ពិសេសស្វាគមន៍ចំនួនអនុសាសន៍ដែលរដ្ឋាភិបាលបានទទួលយកក្នុងអំឡុងពេលពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់លើកទី៣ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការការពារ និងលើកកម្ពស់សិទ្ធិរបស់ជនងាយរងគ្រោះបំផុតនៅកម្ពុជា។[33] សាធារណរដ្ឋបូលីវី វេណេហ្ស៊ុយអេឡា ជាឧទាហរណ៍ បានគូសបញ្ជាក់ពីភាពចាំបាច់ក្នុងការពង្រឹងគោលនយោបាយសង្គមដែលគាំទ្រជនទាំងនោះ ដោយផ្តោតជាពិសេសលើវិស័យដែលងាយរងគ្រោះបំផុត។[34] ប្រទេសកម្ពុជាក៏បានគាំទ្រអនុសាសន៍របស់អូស្ត្រាលី ក្នុងការដាក់ចេញច្បាប់ប្រឆាំងនឹងការរើសអើង គិតត្រឹមឆ្នាំ២០២៣ ដោយធានានូវសមភាព និងហាមឃាត់យ៉ាងច្បាស់ចំពោះការរើសអើងគ្រប់ប្រភេទ រាប់បញ្ចូលទាំង ជំនឿសាសនា និន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការសម្តែងមតិ ឬលក្ខណៈភេទ។[35] អ្នកស្រីលើកទឹកចិត្តរដ្ឋាភិបាលឱ្យធានាថា អនុសាសន៍ដែលបានទទួលយកត្រូវបានអនុវត្តយ៉ាងពេញលេញ និងគោលការណ៍មិនទុកនរណាម្នាក់ចោល គឺជាស្នូលនៃគោលនយោបាយ និងកម្មវិធីរបស់ខ្លួន។

### ១. បុគ្គលត្រូវបានដកហូតសេរីភាព

៣៨. បន្ទាប់ពីទស្សនកិច្ចមួយចំនួន ទៅកាន់មជ្ឈមណ្ឌលសំចតសង្គមកិច្ចរាជធានីភ្នំពេញ (មណ្ឌលព្រៃស្ពឺ) អ្នករាយការណ៍ពិសេសបានធ្វើការសង្កេតយ៉ាងទូលំទូលាយ ដោយលើកឡើងពីកង្វល់អំពីមនុស្សម្នាក់ស្លាប់នៅក្នុងមជ្ឈមណ្ឌល និងអំពាវនាវឱ្យមជ្ឈមណ្ឌលដែលបច្ចុប្បន្នកំពុងបើក ឱ្យបិទទ្វារ។[36] ព័ត៌មានដែលអ្នករាយការណ៍ពិសេសទទួលបានតាមរយៈការិយាល័យ OHCHR បង្ហាញថា មានបុរសអាយុ ៤០ ឆ្នាំម្នាក់ បានស្លាប់នៅក្នុងមជ្ឈមណ្ឌលនេះនៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០។[37] អ្នករាយការណ៍ពិសេសមិនបានទទួលព័ត៌មានអំពីការស៊ើបអង្កេតឯករាជ្យលើករណីនៃការស្លាប់នេះទេ។ លើសពីនេះទៅទៀត វាបង្ហាញថា មជ្ឈមណ្ឌលនេះនៅតែបន្តប្រតិបត្តិការដោយមិនមានរចនាសម្ព័ន្ធអភិបាលកិច្ចច្បាស់លាស់ តម្លាភាព និងគណនេយ្យភាព ក្របខ័ណ្ឌនិងនីតិវិធីច្បាប់ ហើយមជ្ឈមណ្ឌលនេះនៅតែបន្តឃុំខ្លួនមនុស្ស ដែលគេហៅថា មនុស្ស " មិនស្ម័គ្រចិត្ត" ដែលត្រូវអាជ្ញាធរចាប់ប្រមូលយកទៅដាក់។ ទាំងនេះ រួមបញ្ចូលទាំងមនុស្សដែលស្ថិតក្នុងស្ថានភាពរស់នៅតាមចិញ្ចើមផ្លូវ អ្នកប្រើប្រាស់គ្រឿងញៀន និងអ្នករកស៊ីផ្លូវភេទ។ អ្នក

33 សូមមើលផងដែរ របាយការណ៍លេខ A/HRC/42/60/Add.1 ដែលនិយាយអំពីអ្នកដែលទំនងជាត្រូវបានគេទុកចោលក្នុងការអភិវឌ្ឍប្រទេស។

34 របាយការណ៍លេខ A/HRC/41/17 កថាខណ្ឌទី១១០.៥៦ ។

35 របាយការណ៍លេខ A/HRC/41/17 កថាខណ្ឌទី១១០.៥៤ សូមមើលផងដែរ អនុសាសន៍របស់អ៊ុយរូហ្គាយ ត្រង់កថាខណ្ឌទី ១១០.៥៣ ។

36 របាយការណ៍លេខ A/HRC/42/60 កថាខណ្ឌទី៤៨-៤៩ ។

37 យោងតាមព័ត៌មានដែលបានផ្តល់ដោយការិយាល័យ OHCHR បកប្រែពីគេហទំព័រ http://nokorwatnews.com/archives/484174 (ជាភាសាខ្មែរ) និងបញ្ជាក់ដោយសេចក្តីអធិប្បាយដែលទទួលបានពីរដ្ឋាភិបាលឆ្លើយតបនឹងសេចក្តីព្រាងរបាយការណ៍របស់អ្នករាយការណ៍ពិសេស រួមជាមួយនឹងព័ត៌មានលំអិតអំពីការស្លាប់ និងការស៊ើបអង្កេត។

រាយការណ៍ពិសេស នៅតែមានកង្វល់អំពីការឃុំខ្លួនដោយបំពាន និងការរំលោភសិទ្ធិមនុស្សដែលអាចកើតមានផ្សេងទៀតនៅមជ្ឈមណ្ឌលនេះ ក៏ដូចជា កង្វះគណនេយ្យភាព។ ការទទួលបានការថែទាំសុខភាព និងការព្យាបាលឱ្យបានគ្រប់គ្រាន់នៅខាងក្នុងមជ្ឈមណ្ឌលនៅតែជាបញ្ហាប្រឈមដែលជាក្តីកង្វល់ជាពិសេស ទាក់ទងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩។

៣៩. នៅក្នុងដំណើរបេសកកម្មមុនៗ អ្នករាយការណ៍ពិសេស បានធ្វើទស្សនកិច្ច និងបានពិចារណាពីទីតាំងនៃមជ្ឈមណ្ឌលសម្រាប់ការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន។[38] ទាក់ទងនឹងបញ្ហានេះ អ្នករាយការណ៍ពិសេស ស្វាគមន៍ចំពោះសេចក្តីថ្លែងការណ៍ ដែលចេញដោយតំណាងតំបន់នៃទីភ្នាក់ងារអង្គការសហប្រជាជាតិចំនួន១៤ ស្តីពីមណ្ឌលឃុំឃាំង និងនីតិសម្បទាអ្នកញៀនគ្រឿងញៀនជាកំហិតនៅអាស៊ីនិងប៉ាស៊ីហ្វិកក្នុងបរិបទនៃការរីករាលដាលនៃជំងឺកូវីដ-១៩។[39] សេចក្តីថ្លែងការណ៍នេះ បានអំពាវនាវជាពិសេស ចំពោះការបិទជាអចិន្ត្រៃយ៍នូវមជ្ឈមណ្ឌលឃុំឃាំង និងការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនជាកំហិត និងការអនុវត្តសេវាសង្គម សេវាសុខភាពផ្អែកលើសិទ្ធិមនុស្ស និងព័ត៌មានភស្តុតាង និងដោយស្ម័គ្រចិត្ត នៅក្នុងសហគមន៍ ជាវិធានការដ៏សំខាន់មួយ ក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ និងដើម្បីជួយសម្រួលដល់ការងើបឡើងវិញ និងការធ្វើសមាហរណកម្មមនុស្សទាំងអស់ ទៅក្នុងគ្រួសារ និងសហគមន៍របស់ពួកគេ។

៤០. ទាក់ទងនឹងមជ្ឈមណ្ឌលសម្រាប់ការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅកម្ពុជា អ្នករាយការណ៍ពិសេសទទួលបានព័ត៌មានថា គិតត្រឹមថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ មនុស្សសរុប ៦.៥១៧ នាក់ ស្ថិតនៅក្នុងមជ្ឈមណ្ឌលដែលគ្រប់គ្រងដោយរដ្ឋាភិបាលចំនួន ១០.៩៣២ នាក់ នៅតាមមជ្ឈមណ្ឌលដែលគ្រប់គ្រងឯកជន និង ១០០ មជ្ឈមណ្ឌលដែលគ្រប់គ្រងដោយអង្គការមិនមែនរដ្ឋាភិបាល។ ក្របខ័ណ្ឌច្បាប់បច្ចុប្បន្នស្តីពីការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនជាកំហិត រួមមានច្បាប់ឆ្នាំ២០១២ ស្តីពីការគ្រប់គ្រងគ្រឿងញៀន និងសារាចរលេខ០៣ ឆ្នាំ២០០៦ ស្តីពីការអនុវត្តវិធានការស្តីពីការអប់រំការព្យាបាលការស្តារនីតិសម្បទាសម្រាប់អ្នកប្រើប្រាស់គ្រឿងញៀន។ បទប្បញ្ញត្តិទាំងនេះមិនបានបញ្ជាក់ច្បាស់ពីកាលៈទេសៈដែលបុគ្គលម្នាក់ៗ អាចត្រូវបានឃុំខ្លួនដោយមិនស្ម័គ្រចិត្ត និងដែលអាជ្ញាធរមានសមត្ថភាពបញ្ជាឱ្យឃុំខ្លួនជាកំហិតសម្រាប់គោលបំណងនៃការព្យាបាលគ្រឿងញៀន ជាពិសេសថា តើវាអាចធ្វើបានតែដោយព្រះរាជអាជ្ញា ឬយ៉ាងណា។ អ្នករាយការណ៍ពិសេស នៅតែមានកង្វល់ថា ការខ្វះភាពប្រាកដប្រជាបែបនេះ អាចបណ្តាលឱ្យមានការឃុំខ្លួនដោយបំពាន ហើយបញ្ជាក់ជាថ្មីពីកង្វល់របស់គាត់ចំពោះ

[38] របាយការណ៍លេខ A/HRC/42/60 កថាខណ្ឌទី៨៤–៨៧ របាយការណ៍លេខ A/HRC/39/73 កថាខណ្ឌទី៤០-៤៥ ។

[39] គេហទំព័រ https://bangkok.ohchr.org/wp-content/uploads/2020/05/UNJointStatement1June2020.pdf ។

បញ្ហានេះ។[40] លើសពីនេះទៅទៀត វាច្បាស់ណាស់ថា មជ្ឈមណ្ឌលទាំងនេះនៅតែចង្អៀតណែន ដូចជាពន្ធនាគារដែលមានចំនួនប្រជាជនច្រើនត្រូវបានឃុំខ្លួនពីបទគ្រឿងញៀន។[41]

៤១. អ្នករាយការណ៍ពិសេសកត់សម្គាល់ដោយក្តីបារម្ភថាពន្ធនាគារនៅកម្ពុជានៅតែចង្អៀតណែន ដោយការដាក់ជនជាប់ឃុំជាមធ្យមនៅទូទាំងប្រទេសលើសពី ៣០០ ភាគរយនៃសមត្ថភាពដែលអាចដាក់បាន។ យោងតាមព័ត៌មានដែលទទួលបានពីអគ្គនាយកដ្ឋានពន្ធនាគារគិតត្រឹមខែមិថុនា ឆ្នាំ២០២០ មាជនជាប់ឃុំចំនួន ៣៩.៣៧៦ នាក់នៅទូទាំងពន្ធនាគារចំនួន ២៩ ។ មានជនជាប់ឃុំប្រមាណ ២៧ ភាគរយប៉ុណ្ណោះ ដែលបានទទួលសាលក្រមស្ថាពរ រីឯជនជាប់ឃុំ ៣៧ ភាគរយទៀត ត្រូវបានផ្តន្ទាទោសនៅសាលាដំបូងប៉ុន្តែពួកគេនៅតែរង់ចាំលទ្ធផលនៃបណ្តឹងឧទ្ធរណ៍ ដែលធ្វើឱ្យជនជាប់ឃុំ ៣៥ ភាគរយនៃជនដែលជាប់ពន្ធនាគារត្រូវបន្តឃុំខ្លួនបណ្តោះអាសន្នរងចាំសវនាការ។ នេះមិនខុសពីឆ្នាំមុនៗ ទេ។

៤២. អ្នករាយការណ៍ពិសេសស្វាគមន៍គំនិតផ្តួចផ្តើមធ្វើកំណែទម្រង់ដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ថ្មីក្នុងខែឧសភា ឆ្នាំ២០២០ ជាពិសេស ដើម្បីកាត់បន្ថយករណីកកស្ទះនៅសាលាដំបូងនៅទូទាំងប្រទេស ហើយអ្នកស្រីបានផ្តល់ការឧបត្ថម្ភគាំទ្រដល់ការបន្តគ្រប់គ្រងកំណែទម្រង់ប្រព័ន្ធយុត្តិធម៌។ អ្នកស្រីមានសេចក្តីរីករាយដែលដឹងអំពីគោលបំណងរបស់ក្រសួងក្នុងជម្រះសំណុំរឿងពី ៥០ ទៅ ៧០ ភាគរយនៃករណីជិត ៣៩.០០០ ដែលរងចាំការត្រួតពិនិត្យដោយតុលាការរបស់ប្រទេសនេះក្នុងរយៈពេល ៦ ខែ។[42] ការនេះអាចជួយកាត់បន្ថយភាពចង្អៀតណែននៅក្នុងពន្ធនាគារ ហើយសន្មតថារាល់នីតិវិធីត្រឹមត្រូវត្រូវបានអនុវត្តតាម ដោយពង្រឹងការគោរពសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ក្នុងរយៈពេលសមស្រប និងកាត់បន្ថយចំនួនជនជាប់ឃុំបណ្តោះអាសន្ន។

## ២. ជាតិពន្ធុវៀតណាម

៤៣. អ្នករាយការណ៍ពិសេសស្វាគមន៍សេចក្តីណែនាំថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩ ដែលចេញដោយក្រសួងមហាផ្ទៃ ដែលអនុញ្ញាតឱ្យកុមារពីឪពុកម្តាយដែលបានចុះឈ្មោះជាអ្នករស់នៅអចិន្ត្រៃយ៍ទទួលបានសំបុត្រកំណើត។ សេចក្តីណែនាំនេះក៏ស្នើសុំឱ្យអាជ្ញាធរមូលដ្ឋានផ្តល់សៀវភៅស្នាក់នៅ សំបុត្រមរណភាព និងវិញ្ញាបនប័ត្រផ្សេងទៀតដែលបញ្ជាក់ពីសញ្ជាតិ។ ប្រសិនជាអនុវត្តត្រឹមត្រូវ នេះអាចជាជំហានឆ្ពោះទៅរកការធានាសិទ្ធិទទួលបានសញ្ជាតូនីយកម្មសម្រាប់ជាតិពន្ធុវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជា។ អ្នករាយការណ៍ពិសេសក៏កត់សម្គាល់ពីវឌ្ឍនភាពក្នុងការចេញសំបុត្រសំបុត្រកំណើត

40 របាយការណ៍លេខ A/HRC/42/60 កថាខណ្ឌទី៤៧ ។

41 ឯកសារដដែល កថាខណ្ឌទី៤៥ ។

42 គេហទំព័រ www.akp.gov.kh/post/detail/31625 ព័ត៌មានបន្ថែមស្តីពីការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ ការឃុំខ្លួនបណ្តោះអាសន្នរយៈ ពេលវែង និងករណីកកស្ទះ នៅទំព័រ ៤ នៃសេចក្តីអធិប្បាយដែលទទួលបានពីរដ្ឋាភិបាល។

សម្រាប់កុមារជាតិពន្ធុវៀតណាម ដែលពីមុនត្រូវបានគេបដិសេធមិនឱ្យចូលរៀននៅសាលារដ្ឋ ដោយសារពួកគេមិនអាចផលិតសំបុត្រកំណើតចាំបាច់។ អ្នកស្រីលើកទឹកចិត្តឱ្យអាជ្ញាធរ អនុវត្តសេចក្តីណែនាំឱ្យបានពេញលេញ។

៤៤. នៅឆ្នាំ២០២០ ក្រសួងមហាផ្ទៃបានប្រកាសបង្កើតក្រុមការងារ ដើម្បីរៀបចំសេចក្តីព្រាងច្បាប់អន្តោប្រវេសន៍ថ្មី ដើម្បីជំនួសច្បាប់ ឆ្នាំ១៩៩៤។ អ្នករាយការណ៍ពិសេសសង្ឃឹមថា ច្បាប់ថ្មីណាមួយនឹងដោះស្រាយកង្វះខាតនៃនីតិវិធីដែលមានស្រាប់។

៤៥. ដូចដែលបានកត់សម្គាល់កាលពីពេលកន្លងមក ដោយអ្នករាយការណ៍ពិសេស[43] សហគមន៍អណ្តែតទឹកបឹងទន្លេសាប ក្នុងខេត្តកំពង់ឆ្នាំង នៅតែរងផលប៉ះពាល់ដោយសារផែនការផ្លាស់ប្តូរទីលំនៅ ដែលបានធ្វើឡើងសំដៅអភិរក្សជីវៈចម្រុះ និងបរិស្ថាននៃបឹងទន្លេសាប។ នៅក្នុងខេត្តកំពង់ឆ្នាំង បន្ទាប់ពីមានការតស៊ូមតិរួមគ្នាពីការិយាល័យប្រចាំប្រទេសនៃការិយាល័យ OHCHR ប្រចាំកម្ពុជា និងអ្នករាយការណ៍ពិសេស អាជ្ញាធរខេត្តបានចូលរួមក្នុងដំណើរការ ដើម្បីកំណត់អត្តសញ្ញាណដី និងកំណត់ព្រំដែន ដើម្បីផ្លាស់ទីលំនៅប្រជាជនប្រមាណ ១ ម៉ឺននាក់ ដែលមានទាំងជនជាតិខ្មែរ និងជាតិពន្ធុវៀតណាម ពីភូមិអណ្តែតទឹក។ គំនិតផ្តួចផ្តើមបែបនេះ ត្រូវតែបានកោតសរសើរ។ ទោះយ៉ាងណាក៏ដោយនៅតែមានភាពប្រទាំងប្រទិស ក្នុងការទទួលបានសេវាដោយស្មើភាពគ្នា ចំពោះសហគមន៍អណ្តែតទឹកជាតិពន្ធុវៀតណាម។

៤៦. សហគមន៍ជាតិពន្ធុវៀតណាមនៅតែស្ថិតក្នុងស្ថានភាពងាយរងគ្រោះ។ កុមារជាតិពន្ធុវៀតណាមជាច្រើនបោះបង់ចោលការសិក្សា ហើយត្រូវទទួលរងការរើសអើងពីមិត្តភក្តិជាជនជាតិខ្មែរ និងគ្រូរបស់ពួកគេ ដោយសារតែដើមកំណើតជាតិពន្ធុរបស់ពួកគេ និងដោយសារពួកគេនិយាយភាសាខ្មែរមិនបានស្ទាត់ជំនាញ។ បន្ទាប់មក ឱកាសការងាររបស់ពួកគេអាចមានកំណត់ ដោយមិនមានឯកសារបញ្ជាក់អត្តសញ្ញាណជនជាតិខ្មែរ និងឬដោយសារកង្វះជំនាញភាសាខ្មែរ។

## IV. សិទ្ធិមនុស្ស និងការឆ្លើយតបទៅនឹងជំងឺកូវីដ-១៩

៤៧. ជំងឺកូវីដ-១៩ បានរាលដាលមកដល់ប្រទេសកម្ពុជា ហើយមានភស្តុតាងនៃការឆ្លើយតបរបស់រដ្ឋាភិបាលដែលមានការសម្របសម្រួល ទៅនឹងការគំរាមកំហែងនេះ។ មាត្រា ៧២ នៃរដ្ឋធម្មនុញ្ញធានាការពារសុខភាពប្រជាជន សិទ្ធិនេះក៏ត្រូវបានទទួលយកនៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិជាច្រើនដែលបានផ្តល់សច្ចាប័ន មិនត្រឹមតែជាកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ប៉ុណ្ណោះទេ។ ការណែនាំទូលំទូលាយស្តីពីអភិក្រមផ្អែកលើសិទ្ធិក្នុងការនាំមុខ ក្នុងពេលមានជំងឺរាតត្បាតអាចរកបានពី

[43] របាយការណ៍លេខ A/HRC/42/60 ។

នីតិវិធីពិសេស [44] ស្ថាប័នសន្ធិសញ្ញា [45] និងស្ថាប័នដទៃទៀត។ [46] ស្ថានភាពនេះកំពុងបន្ត ដូច្នេះការវិភាគខាងក្រោមនេះ គឺជាជំហានដំបូង។

៤៨. នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០ អង្គការសុខភាពពិភពលោក បានកត់ត្រាករណីដែលបានបញ្ជាក់ មានចំនួន១៤១ ករណីជំងឺកូវីដ-១៩ នៅកម្ពុជា ប៉ុន្តែមិនមានអ្នកស្លាប់ទេ។[47] វិទ្យាស្ថានប៉ាស្ទ័រនៅកម្ពុជាបានរាយការណ៍ថា ក្នុងរយៈពេលចាប់ពីថ្ងៃទី២២ ខែមករា ដល់ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២០ វិទ្យាស្ថានបានធ្វើតេស្តលើមនុស្សជាង ១៣.៨៧០ នាក់ និងយកសំណាកចំនួន ១៦.៥០៦ នាក់ សម្រាប់ធ្វើវិភាគរកជំងឺកូរ៉ូណាថ្មី។ ការធ្វើតេស្ត គឺនៅរាជធានីភ្នំពេញ។ អ្នករាយការណ៍ពិសេស មិនច្បាស់ទេថា តើប្រជាជនដែលបាត់បង់ឱកាស និងប្រជាជនងាយរងគ្រោះដែលរស់នៅក្រៅរាជធានីភ្នំពេញមានសិទ្ធិទទួលបានការធ្វើតេស្តដោយស្មើភាពគ្នា និងព័ត៌មានទាក់ទងនឹងវិធានការសុខភាពសាធារណៈដែលបានណែនាំដោយរដ្ឋាភិបាល ឬយ៉ាងណា។

៤៩. នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ រដ្ឋាភិបាលបានអនុញ្ញាតឱ្យនាវាទេសចរណ៍ប្រទេសហូឡង់អាមេរិចកាំងមួយឈ្មោះវ៉េសស្ទើដាម (MV Westerdam) ចូលចតនៅក្រុងព្រះសីហនុនៅភាគខាងត្បូងនៃប្រទេស បន្ទាប់ពីនាវានេះត្រូវបានគេបដិសេធមិនឱ្យចូលប្រទេសជាច្រើននៅអាស៊ីដោយសារតែការព្រួយបារម្ភលើជំងឺកូវីដ-១៩។ នាវានេះមិនបានគ្រោងនឹងមកទស្សនាប្រទេសកម្ពុជាទេ។ ការសម្រេចចិត្តរបស់កម្ពុជា ត្រូវបានស្វាគមន៍ដោយអគ្គនាយកនៃអង្គការសុខភាពពិភពលោក ថាជាឧទាហរណ៍មួយនៃសាមគ្គីភាពអន្តរជាតិ។[48]

៥០. អ្នករាយការណ៍ពិសេស មានការជឿជាក់លើវិធានការដែលបានដាក់ចេញដោយអាជ្ញាធរកម្ពុជាទាក់ទងនឹងការរកករណី រកអ្នកប៉ះពាល់ និងវិធានការចត្តាឡីស័កសម្រាប់អ្នកដែលមានទំនាក់ទំនងជាមួយអ្នកដែលបានធ្វើតេស្តវិជ្ជមាន ទោះបីជាអ្នកស្រីមានការព្រួយបារម្ភអំពីដំណើរការទិន្នន័យ និងសន្តិសុខក៏ដោយ។ អាជ្ញាធរបានចាត់វិធានការយ៉ាងឆាប់រហ័ស ដើម្បីការពារសុខភាពប្រជាជននៅក្នុងប្រទេសកម្ពុជា និងបានស្វែងរកអនុវត្តតាមពិធីសារអន្តរជាតិស្តីពីចត្តាឡីស័ក។ ក្រសួងសុខាភិបាលបានផ្តល់ព័ត៌មានសង្ខេប និងធ្វើបច្ចុប្បន្នភាពជាប្រចាំ។ អ្នករាយការណ៍ពិសេស រំលឹកដល់អាជ្ញាធរកម្ពុជាឱ្យបន្តគិតពិចារណាឱ្យបានពេញលេញចំពោះការបង្ការ និងព្យាបាលជំងឺ ជាសិទ្ធិមួយដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ហើយគោរពឱ្យបានពេញលេញនូវកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ រួមទាំងសិទ្ធិទទួលបានស្តង់ដារសុខភាពខ្ពស់បំផុត ដូចមានចែងក្នុងមាត្រា១២

[44] គេហទំព័រ www.ohchr.org/EN/HRBodies/SP/Pages/COVID-19-and-Special-Procedures.aspx ។

[45] គេហទំព័រ www.ohchr.org/EN/HRBodies/Pages/COVID-19-and-TreatyBodies.aspx ។

[46] គេហទំព័រ www.ohchr.org/EN/NewsEvents/Pages/COVID-19.aspx ។

[47] គេហទំព័រ https://covid19.who.int ។

[48] គេហទំព័រ www.who.int/dg/speeches/detail/who-director-general-s-opening-remarks-at-the-media-briefing-on-ebola-and-covid-19-outbreak ។

នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយគ្មានការរើសអើង។

៥១. ដៃគូអភិវឌ្ឍន៍មួយចំនួននៃប្រទេសកម្ពុជា បានផ្តល់ការគាំទ្រ និងជំនាញក្នុងបញ្ហានេះ។ ការគាំទ្របែបនេះ គួរតែជួយរដ្ឋាភិបាលក្នុងការរៀបចំឱ្យកាន់តែប្រសើរសម្រាប់វិបត្តិសេដ្ឋកិច្ចសាធារណៈដែលអាចកើតមាន និងដើម្បីរៀបចំពិធីសារទាក់ទងនឹងគ្រោះមហន្តរាយដែលពាក់ព័ន្ធ។ ការការពារសិទ្ធិមនុស្សសម្រាប់មនុស្សគ្រប់គ្នា ត្រូវតែជាចំណុចស្នូលរបស់រដ្ឋាភិបាល និងជាការឆ្លើយតបចំពោះវិបត្តិណាមួយ។ ទោះបីការការពារសុខភាពពិតជាអាទិភាពមួយនាពេលបច្ចុប្បន្នក៏ដោយ ក៏សិទ្ធិទាំងអស់ចាំបាច់ត្រូវគិតពិចារណាឱ្យបានម៉ត់ចត់ និងចាត់វិធានការ ដើម្បីធានាថាគ្មាននរណាម្នាក់ត្រូវបានគេទុកចោលឡើយ។

## ក. ការរឹតត្បិតសិទ្ធិមនុស្ស ក្នុងបរិបទនៃការរីករាលដាលនៃជំងឺកូវីដ-១៩

៥២. នៅពាក់កណ្តាលខែមីនា ឆ្នាំ២០២០ កម្ពុជាបានដាក់ឱ្យអនុវត្តការរឹតបន្តឹងការធ្វើដំណើរចូលប្រទេសនេះ ក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីបង្ការការឆ្លងបន្ថែមនៃជំងឺកូវីដ-១៩ ។ នៅចុងខែមីនា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានពង្រីកការរឹតត្បិតចំពោះជនបរទេសទាំងអស់។ ទន្ទឹមនេះដែរ ក៏អនុវត្តចំពោះជនជាតិខ្មែរនៅបរទេស ដែលវិលត្រឡប់មកប្រទេសកម្ពុជាវិញ រួមទាំងពលករចំណាកស្រុក ត្រូវបានគេណែនាំអំពីដំណើរការនៃការផ្តាច់ខ្លួនដោយខ្លួនឯងក្រៅផ្លូវការ។

៥៣. ក្រសួងអប់រំយុវជន និងកីឡា បានប្រកាសបិទសាលារៀន និងគ្រឹះស្ថានអប់រំសាធារណៈ និងឯកជនទាំងអស់ ចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០។ កិច្ចការសហសម័យបានចាប់ផ្តើមផ្តួចផ្តើមការរៀនតាមប្រព័ន្ធអេឡិកត្រូនិក និងផលិតសម្ភារៈអប់រំការរៀនសូត្រពីចម្ងាយ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងប្រទេសជាច្រើនទៀត មាតាបីតាអាណាព្យាបាល និងសិស្ស មិនបានត្រៀមសម្រាប់ការផ្លាស់ប្តូរមួយដ៏ខ្លី ឈានទៅការរៀននៅផ្ទះ ការសិក្សាកម្រិតឧត្តមសិក្សាពីចម្ងាយឡើយ។ យោងតាមអង្គការអប់រំវិទ្យាសាស្ត្រ និងវប្បធម៌នៃអង្គការសហប្រជាជាតិ (UNESCO) បានឱ្យដឹងថា សិស្សសាលាបឋមសិក្សា និងមធ្យមសិក្សាប្រមាណ ៦៣ ភាគរយ (២,០៧ លាននាក់) មិនអាចចូលរៀនកម្មវិធីអេឡិចត្រូនិក និងកម្មវិធីសិក្សាពីចម្ងាយបានទេ ព្រោះពួកគេមិនមានលទ្ធភាពទិញឧបករណ៍ ឬបង់ថ្លៃការចូលប្រើអ៊ីនធឺណិត។ អ្នករាយការណ៍ពិសេស ក៏មានការព្រួយបារម្ភផងដែរថា ដោយសារទំនៀមទំលាប់យេនឌ័រ ក្មេងស្រីអាចទទួលបានអត្ថប្រយោជន៍តិចពីការរៀនសូត្រតាមអ៊ិនធឺណិត ជាពិសេស កន្លែងដែលពួកគេមានលទ្ធភាពប្រើប្រាស់ឧបករណ៍។ ពួកគេក៏អាចត្រូវបានគេរំពឹងថានឹងអនុវត្តការងារថែទាំដោយមិនយកប្រាក់ជំនួសការអប់រំពីចម្ងាយ។ អ្នករាយការណ៍ពិសេស កត់សម្គាល់ពីការឆ្លើយតបលម្អិតរបស់រដ្ឋាភិបាល រួមមានព័ត៌មានលម្អិតស្តីពីការបើកឡើងវិញនូវកន្លែងសិក្សា និងការបន្តការបង្រៀនដោយផ្ទាល់។

៥៤. រដ្ឋាភិបាលបានដាក់ចេញនូវការកម្រិតកំណត់មួយចំនួនលើសេរីភាពក្នុងការដើរហើរ សេរីភាពក្នុងការជួបប្រជុំ និងសេរីភាពខាងសមាគម និងសេរីភាពក្នុងការគោរពប្រតិបត្តិសាសនាក្នុងសហគមន៍ជាមួយអ្នកដទៃ ដើម្បីកាត់បន្ថយការឆ្លង និងការរីករាលដាលក្នុងសហគមន៍នៃជំងឺកូវីដ-១៩។ ពិធីអបអរសាទរបុណ្យចូលឆ្នាំខ្មែរនៅខែមេសា ត្រូវបានលុបចោល ហើយការធ្វើដំណើរត្រូវបានរឹតបន្តឹងរយៈពេលជាច្រើនថ្ងៃ។ ក្រសួងសុខាភិបាលបានហាមប្រាមការប្រមូលផ្តុំផ្សេងទៀត រួមទាំងការជួបជុំខាងសាសនាដែលមានទ្រង់ទ្រាយធំផងដែរ។ អ្នករាយការណ៍ពិសេសកត់សម្គាល់ថា ការរឹតត្បិតបែបនេះទៅលើការទទួលបានសិទ្ធិមនុស្ស អាចត្រូវបានអនុញ្ញាតក្នុងកាលៈទេសៈជាក់លាក់ជាពិសេសប្រសិនបើរឹតត្បិតទាំងនោះមានសមាមាត្រទៅនឹងហានិភ័យ ហើយមានតែក្នុងកម្រិតចាំបាច់ ដើម្បីសម្រេចគោលបំណងសុខភាពសាធារណៈតែប៉ុណ្ណោះ។

៥៥. នៅខែមេសា ឆ្នាំ២០១៩ ព្រឹទ្ធសភាកម្ពុជា បានអនុម័តច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ដែលកសាងបន្ថែមលើបទប្បញ្ញត្តិពាក់ព័ន្ធនៃរដ្ឋធម្មនុញ្ញជាពិសេស មាត្រា២២។ នៅក្នុងសេចក្តីថ្លែងការណ៍មួយ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០ អ្នករាយការណ៍ពិសេស រួមជាមួយអ្នកកាន់អាណត្តិមួយចំនួន បានគូសបញ្ជាក់ថាច្បាប់ដែលត្រូវបានអនុម័តនាពេលបច្ចុប្បន្ននេះ អាចត្រូវបានប្រើដើម្បីរឹតបន្តឹងសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ សិទ្ធិសេរីភាពខាងសមាគម និងសិទ្ធិជួបប្រជុំដោយសន្តិវិធី និងសិទ្ធិក្នុងការដើរហើរ ដូចមានចែងក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។[49] អ្នកជំនាញទាំងនោះ បានសម្តែងផងដែរនូវការព្រួយបារម្ភទាក់ទងទៅនឹងភាសាដែលនិយាយយ៉ាងទូលំទូលាយ ស្តីពីអំណាច និងការពិន័យ រួមទាំងការផ្តន្ទាទោសដាក់ពន្ធនាគាររហូតដល់ ១០ ឆ្នាំ ចំពោះអ្នកដែលត្រូវបានរកឃើញថា រំលោភច្បាប់នេះ។[50] ការឆ្លើយតបរបស់រដ្ឋាភិបាល បានព្យាយាមបញ្ជាក់ថា អំណាចនេះនឹងត្រូវបានអនុវត្តតែក្នុងស្ថានភាពមួយ ដែលត្រូវការវិធានការបន្ថែមចាំបាច់បំផុត ក្នុងការ ធានាការពារ និងថែរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ដើម្បីការពារអាយុជីវិតប្រជាជន សុខភាពសាធារណៈ ផលប្រយោជន៍សាធារណៈ និងទ្រព្យសម្បត្តិរបស់ប្រជាជនកម្ពុជាទាំងមូល។[51] អ្នករាយការណ៍ពិសេស កត់សម្គាល់ថា ការរាតត្បាតនៃជំងឺកូវីដ-១៩ មិនបានបង្ហាញថាឈានដល់កំរិតនេះទេ។

៥៦. ក្នុងករណីណាមួយ ដែលរដ្ឋាភិបាលប្រកាសដាក់ប្រទេសក្នុងភាពអាសន្ន រដ្ឋាភិបាលត្រូវជូនដំណឹងអំពីសិទ្ធិមួយចំនួនដែលត្រូវដកហូត ដែលមានចែងក្នុងសន្ធិសញ្ញា ដែល

---

49 ការិយាល័យ OHCHR ឧបាស្រ័យលេខ OL KHM 1/2020 ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០២០។ អាចរកបាននៅលើគេហទំព័រ https://spcommreports.ohchr.org ។

50 គេហទំព័រ ww.ohchr.org/EN/NewsEvents/Pages/DisplayNews.aspx?NewsID=25801&LangID ។

51 គេហទំព័រ https://spcommreports.ohchr.org/TMResultsBase/DownLoadFile?gId=35228 (កថាខណ្ឌទី ៨) ។

បានផ្តល់សច្ចាប័នស្របតាមច្បាប់អន្តរជាតិពាក់ព័ន្ធ។[52] កម្ពុជា មិនអាចដកហូតទាំងស្រុងនូវសិទ្ធិសេរីភាពទាំងឡាយដែលត្រូវបានការពារឡើយ។ សិទ្ធិសេរីភាពទាំងអស់ នៅតែអាចអនុវត្តបានយ៉ាងពេញលេញជាដដែល។ ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន នៅតែគោរពអនុវត្ត។

៥៧. នៅចុងខែឧសភា ឆ្នាំ២០២០ កម្ពុជាបានចាប់ផ្តើមបន្ធូរបន្ថយការរឹតត្បិតលើការធ្វើដំណើរចូលប្រទេស។ នេះគឺជាការអនុវត្តប្រព័ន្ធសាកល្បងសម្រាប់អ្នកដែលចូលមក ប្រទេសកម្ពុជា និងលក្ខខណ្ឌតម្រូវឱ្យដាក់នៅដាច់ដោយឡែករយៈពេល ១៤ ថ្ងៃ។ អ្នករាយការណ៍ពិសេស អំពាវនាវឱ្យរដ្ឋាភិបាលរៀបចំផែនការនេះដោយប្រុងប្រយ័ត្ន ដើម្បីធានាថាវិធានការដាក់ឱ្យនៅដាច់ដោយឡែកណាមួយ មិនបង្កើតទៅជាការឃុំឃាំងដោយខុសច្បាប់ និងធានាសុវត្ថិភាព និងសន្តិសុខរបស់ប្រជាជន។ ការនេះ ក៏ចាំបាច់ផងដែរដើម្បីធានាថាអ្នកដែលដាក់ឱ្យនៅដាច់ដោយឡែក ត្រូវបានផ្តល់ការផ្គត់ផ្គង់សំខាន់ៗមួយចំនួន រួមមានអាហារ ទឹក និងថ្នាំពេទ្យ។

## ខ. សិទ្ធិទទួលបានកម្រិតសុខភាពខ្ពស់បំផុត

៥៨. កម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ក្នុងការលើកកំពស់សិទ្ធិរបស់ប្រជាជនកម្ពុជាគ្រប់រូបឱ្យទទួលបានកម្រិតខ្ពស់បំផុតខាងសុខភាពរាងកាយ។ ក្រសួងសុខាភិបាលមានផែនការយុទ្ធសាស្ត្រសុខាភិបាល និងផែនការប្រព័ន្ធព័ត៌មានសុខាភិបាល ហើយក្រសួងបាននិងកំពុងធ្វើការឈានទៅលើកកម្ពស់គុណភាព និងការផ្តល់ការថែទាំសុខភាពនៅក្នុងប្រទេស រួមទាំងសេវាកម្មសហគមន៍សម្រាប់អ្នកដែលមានបញ្ហាញៀនគ្រឿងញៀនមិនអាចផ្តាច់បាន។[53] ទោះជាយ៉ាងណាក៏ដោយ ក៏នៅតែមានភាពចាំបាច់សម្រាប់វឌ្ឍនភាពបន្ថែមទៀត មុនពេលប្រជាជនកម្ពុជាទាំងអស់ អាចទទួលបានអត្ថប្រយោជន៍ពីសិទ្ធិទទួលបានកម្រិតខ្ពស់បំផុតខាងសុខភាពផ្លូវកាយ និងផ្លូវចិត្ត។

៥៩. មានការឆ្លើយតបរបស់រដ្ឋាភិបាលដែលមានការសម្របសម្រួលចំពោះការគំរាមកំហែងដល់សុខភាពសាធារណៈដោយជំងឺកូរ៉ូណាថ្មី។ ទោះជាយ៉ាងណាក៏ដោយ អ្នករាយការណ៍ពិសេស បានទទួលព័ត៌មានថា វិធានការសុខភាពសាធារណៈមិនទទួលបានស្មើភាពគ្នាចំពោះប្រជាជនដែលងាយរងគ្រោះបំផុត រួមមានជនជាតិដើមភាគតិច សហគមន៍ជនជាតិវៀតណាម និងជនពិការ។ ក្រុមទាំងនេះខ្លះ មិននិយាយភាសាខ្មែរ និងមិនមានលទ្ធភាពទទួលបានព័ត៌មានផ្លូវការ។ គំនិតផ្តួចផ្តើមមានកំណត់ ក្នុងការផ្សព្វផ្សាយព័ត៌មានដល់

52 សូមមើលឧទាហរណ៍ របាយការណ៍លេខ CCPR/C/128/2។

53 របាយការណ៍លេខ A/HRC/39/73 ។

សហគមន៍ជនជាតិដើមភាគតិច និងជនជាតិវៀតណាម ត្រូវបានអនុវត្តដោយឈរលើមូលដ្ឋានចំពោះកិច្ច។ ព័ត៌មានផ្លូវការភាគច្រើន មិនមានក្នុងទម្រង់ដែលជនពិការអាចរកបាន។[54]

## គ. សិទ្ធិនារី

៦០. អ្នករាយការណ៍ពិសេស មានការព្រួយបារម្ភថា ការចូលរួមរបស់ស្ត្រីក្នុងសកម្មភាពសេដ្ឋកិច្ច ជាពិសេសនៅក្នុងវិស័យក្រៅប្រព័ន្ធ បានរងផលប៉ះពាល់ខ្លាំងដោយការរាតត្បាតនៃជំងឺ-១៩។ ដូចបានកត់សម្គាល់ខាងលើ ការបិទរោងចក្រដែលមានផលប៉ះពាល់មិនសមាមាត្រដល់ស្ត្រី ជាពិសេស នៅក្នុងវិស័យកាត់ដេរ។ ដោយសារវិធានការរឹតត្បិត និងតម្រូវការចាំបាច់សម្រាប់ការរក្សាគំលាតសង្គម ស្ត្រីដែលធ្វើការក្នុងឧស្សាហកម្មម៉ាស្សា និងសេវាកម្មភោជនីយដ្ឋាន ដែលអ្នកខ្លះជាមេគ្រួសាររកប្រាក់ចិញ្ចឹមគ្រួសារតែម្នាក់ឯង បានបាត់បង់ប្រាក់ចំណូលរបស់ពួកគេ។ យោងតាមការវាយតំលៃសេដ្ឋកិច្ចសង្គមយ៉ាងឆាប់រហ័ស នៅក្នុងប្រទេសកម្ពុជា ដោយគម្រោងអ៊ីមផៅវ័រ ស្ត្រីទាំងអស់ដែលត្រូវបានស្ទង់មតិ បានរាយការណ៍ថា មានការធ្លាក់ចុះនូវប្រាក់ចំណូល និងការងារ ដែលក្នុងនោះ ៦៩ ភាគរយ ជាមេគ្រួសារដែលប្រាក់ចំណូលចម្បងសម្រាប់គ្រួសាររបស់ពួកគេ។[55]

៦១. អ្នករាយការណ៍ពិសេស មានការព្រួយបារម្ភបន្ថែមទៀតថា ការបង្ខាំងស្ត្រីដោយសារតែការរឹតត្បិតលើការធ្វើដំណើរ និងតម្រូវការដាក់ឱ្យនៅដាច់ដោយឡែកពីគ្នា បានបង្កើនហានិភ័យនៃជម្លោះ និងអំពើហឹង្សាក្នុងគ្រួសារ ហើយគណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ បានសម្តែងការព្រួយបារម្ភរួចហើយ ទៅលើអំពើហឹង្សាប្រឆាំងនឹងស្ត្រីភេទ។[56] ស្ត្រី និងកុមារី ជាពិសេស ក្នុងដំណាក់កាលមានគភ៌ និងសម្រាលកូននឹងទទួលរងផលប៉ះពាល់យ៉ាងច្រើនពីការឆ្លងបន្ថែមទៀតនូវជំងឺកូវីដ-១៩ ដោយសារប្រព័ន្ធគាំពារសុខភាពនៅថ្នាក់មូលដ្ឋាន មិនបានរៀបចំឱ្យបានត្រឹមត្រូវ ហើយស្ត្រីកម្ពុជាបានសម្តែងការព្រួយបារម្ភចំពោះហានិភ័យនៃការឆ្លងជំងឺជំងឺកូវីដ-១៩ ដោយមន្ទីរសំរាកព្យាបាល ឬមជ្ឈមណ្ឌលគាំពារសុខភាពដទៃផ្សេងទៀត។ ការចំណាយពេលវេលាច្រើនដោយស្ត្រីទៅលើការមើលថែទាំគ្មានប្រាក់កម្រៃ និងការងារផ្ទះ បានកើនឡើងផងដែរ ដោយស្ទើរតែមួយភាគបីនៃស្ត្រីដែលត្រូវបានស្ទង់មតិដោយគម្រោងអេមផៅវ័រ បង្ហាញថាបានកើនឡើងទ្វេរដង។ ដោយសារបទដ្ឋានយេនឌ័របែបប្រពៃណី ក្មេងស្រី អាចទទួលបានអត្ថប្រយោជន៍តិចតួចពីការរៀនសូត្រតាមអ៊ិនធឺណិត ហើយផ្ទុយទៅវិញគេរំពឹងថាការងារថែទាំគ្មានប្រាក់កម្រៃ នឹងមានការកើនឡើង។

---

54 សូមមើលឯកសារពីអ្នករាយការណ៍ពិសេសស្តីពីសិទ្ធិជនដែលមានពិការភាព អង្គការសុខភាពពិភពលោក និងអង្គភាពនានារបស់អង្គការសហប្រជាជាតិ ដែលអាចរកបាននៅលើ www.ohchr.org/EN/HRBodies/SP/Pages/COVID-19-and-Special-Procedures.aspx ។

55 "ផលប៉ះពាល់នៃជំងឺកូវីដ-១៩ ទៅលើស្ត្រី និងសហគ្រាសជនបទ៖ ការវាយតំលៃសេដ្ឋកិច្ចសង្គមដ៏ឆាប់រហ័សនៅប្រទេសកម្ពុជាដោយគម្រោង EmPower" (២០២០) ។ អាចរកបាននៅលើគេហទំព័រ www.empowerforclimate.org ។

56 របាយការណ៍លេខ CEDAW/C/KHM/CO/6 កថាខណ្ឌទី២៤ ។

## ឃ. ការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌

៦២. ភាពចង្អៀតណែននៅក្នុងពន្ធនាគារបង្កជាហានិភ័យដ៏ធំមួយសម្រាប់ការឆ្លងជំងឺកូវីដ-១៩ ហើយវាក៏ជាបញ្ហាប្រឈមសម្រាប់សិទ្ធិមនុស្សផ្សេងទៀតផងដែរ។ អ្នករាយការណ៍ពិសេស លើកទឹកចិត្តឱ្យរដ្ឋាភិបាលបញ្ចូលគោលការណ៍ណែនាំដែលបានផ្តល់ដោយក្រុមការងារស្តីពីការឃុំខ្លួនដោយបំពាន ក្នុងផែនការរបស់ខ្លួនលេខ១១ ស្តីពីការបង្ការការដកហូតសិទ្ធិសេរីភាពក្នុងបរិបទនៃភាពអាសន្នផ្នែកសុខភាពសាធារណៈ។[57]

៦៣. នៅខែមីនាឆ្នាំ២០២០ ក្រសួងមហាផ្ទៃបានដាក់ចេញនូវវិធានការមួយចំនួនដែលមានគោលដៅទប់ស្កាត់ការរីករាលដាលនៃជំងឺ-១៩ នៅក្នុងពន្ធនាគារ រួមមានការហាមឃាត់ជាបណ្តោះអាសន្នរាល់ការជួបសួរសុខទុក្ខអ្នកជាប់ឃុំនៅគ្រប់ពន្ធនាគារ និងការណែនាំជាបន្តបន្ទាប់សម្រាប់ការធ្វើចត្តាឡីស័កជំងឺកូវីដ-១៩ រយៈពេល១៤ថ្ងៃ និងការដាក់ឱ្យនៅដាច់ដោយឡែកចំពោះអ្នកជាប់ឃុំទាំងអស់ដែលទើបចូលថ្មី។ អ្នករាយការណ៍ពិសេសកត់សម្គាល់ថា នៅថ្ងៃទី១៦ ខែមេសា អគ្គនាយកដ្ឋានពន្ធនាគារបានលុបចោលការហាមឃាត់តាមព្រឹត្តន័យចំពោះការហៅទូរស័ព្ទរបស់អ្នកទោស និងអ្នកជាប់ឃុំ។ ក្រសួងមហាផ្ទៃ ក៏បានប្រកាសបង្កើនកិច្ចសហប្រតិបត្តិការជាមួយក្រសួងសុខាភិបាល ដើម្បីតាមដានយ៉ាងដិតដល់ និងធ្វើឱ្យប្រសើរឡើងដល់សុខភាពអ្នកជាប់ឃុំក្នុងពន្ធនាគារ និងឆ្លើយតបរាល់វិបត្តិសុខភាពនៅក្នុងពន្ធនាគារ។[58]

៦៤. គំនិតផ្តួចផ្តើមទាំងនេះត្រូវបានស្វាគមន៍ ប៉ុន្តែវាមានលក្ខណៈជាបណ្តោះអាសន្នតែប៉ុណ្ណោះ។ អ្នករាយការណ៍ពិសេសលើកទឹកចិត្តឱ្យរដ្ឋាភិបាលពង្រឹងជម្រើសជំនួសការឃុំឃាំង ធ្វើការកែទម្រង់ចាំបាច់ដល់ច្បាប់និងគោលនយោបាយ ដើម្បីបន្ធូរបន្ថយការបង់ប្រាក់ធានានៅក្រៅឃុំ និងការឃ្លាំមើលតុលាការ និងធានាឱ្យការអនុវត្តមានប្រសិទ្ធភាពគឺជាបញ្ហាអាទិភាព ដើម្បីកាត់បន្ថយភាពចង្អៀតណែនក្នុងពន្ធនាគារ។ ក្នុងបរិបទនេះ អ្នកស្រីបានកត់សម្គាល់ពីការប្តេជ្ញាចិត្តជាថ្មីរបស់ក្រសួងមហាផ្ទៃ ក្នុងការធ្វើការជាមួយក្រសួងយុត្តិធម៌ ដើម្បីដោះស្រាយភាពចង្អៀតណែននៅក្នុងពន្ធនាគារ។

## ង. សិទ្ធិធ្វើការ និងមានកម្រិតជីវភាពរស់នៅនៅសមរម្យ

៦៥. អ្នករាយការណ៍ពិសេស កត់សម្គាល់ថា កម្ពុជាមានស្ថានភាពការងារស្មុគស្មាញដែលគ្របដណ្តប់លើវិស័យសាធារណៈ និងវិស័យឯកជន ក៏ដូចជាវិស័យក្នុងប្រព័ន្ធ និងវិស័យក្រៅប្រព័ន្ធដែលកំពុងកើនឡើង។ មនុស្សជាច្រើនកាន់ការងារច្រើន ឬប្រើជម្រើសផ្សេងៗដើម្បីបង្កើតប្រាក់ចំណូល ដើម្បីធានាបាននូវកម្រិតជីវភាពរស់នៅសមរម្យ។ ឆ្លើយតបនឹងការរាតត្បាតនៃជំងឺកូវីដ-១៩ នៅកម្ពុជា បានជះឥទ្ធិពលអវិជ្ជមានដល់សិទ្ធិការងារ

[57] គេហទំព័រ www.ohchr.org/Documents/Issues/Detention/DeliberationNo11.pdf (កថាខណ្ឌទី២២) ។

[58] សេចក្តីប្រកាសអន្តរក្រសួងរបស់ក្រសួងមហាផ្ទៃ និងក្រសួងសុខាភិបាល ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសសុខភាពពន្ធនាគារចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០ ។

និងកម្រិតជីវភាពរស់នៅសមរម្យសម្រាប់មនុស្សជាច្រើន។ ការប្រកបរបរចិញ្ចឹមជីវិតក៏ទំនងជាត្រូវបានរងផលប៉ះពាល់ដោយការសម្រេចចិត្តមួយជាច់ដោយឡែក ដែលបានធ្វើឡើងដោយសហភាពអឺរ៉ុបក្នុងការដកប្រព័ន្ធអនុគ្រោះពន្ធពាណិជ្ជកម្មជាក់លាក់។[59] សិទ្ធិត្រូវបានវិភាគដូចខាងក្រោម ដោយការរួមបញ្ចូលគ្នានៃផលប៉ះពាល់សេដ្ឋកិច្ចសង្គម។ ការយល់ដឹង គួរតែត្រូវបានផ្តល់ជាព័ត៌មានលម្អិតនៃការឆ្លើយតបរបស់រដ្ឋាភិបាលចំពោះជំងឺកូវីដ-១៩ ដូចដែលបានរៀបរាប់នៅក្នុងឧបសម្ព័ន្ធក្រោម កថាខ័ណ្ឌទី៦៥ ។

៦៦. កាលពីពេលថ្មីៗនេះ អ្នករាយការណ៍ពិសេស បានសម្តែងការព្រួយបារម្ភអំពីសិទ្ធិការងារនៅកម្ពុជា រួមទាំងការរើសអើង និងសហជីពផងដែរ។ អ្នកស្រីបានពិចារណាពីស្ថានភាពរបស់ប្រជាជនដែលបាត់បង់ឱកាស រួមទាំង ស្ត្រី ពលករទេសន្តប្រវេសន៍ ក្រុមអ្នកធ្វើចំណាកស្រុក និងមនុស្សដែលស្ថិតក្នុងស្ថានភាពរស់នៅតាមចិញ្ចើមផ្លូវ។[60] អំពីសហជីពកម្មករវិញ អ្នករាយការណ៍ពិសេស បានស្វាគមន៍ចំពោះដំណើរការពិគ្រោះយោបល់ ដើម្បីពិនិត្យច្បាប់ស្តីពីសហជីព[61] ប៉ុន្តែអ្នកស្រីមានការសោកស្តាយដែលការធ្វើវិសោធនកម្មនេះមិនទាន់ធានានូវការអនុវត្តន៍ច្បាប់ ស្របតាមបទដ្ឋានសិទ្ធិមនុស្ស និងបទដ្ឋានទាំងឡាយដែលពាក់ព័ន្ធរបស់អង្គការពលកម្មអន្តរជាតិ ។ ការធ្វើវិសោធនកម្មត្រូវបានរាយឈ្មោះនៅក្នុងសេចក្តីផ្តល់មតិ ដែលរដ្ឋាភិបាលបានទទួល ទាក់ទងនឹងកថាខណ្ឌ ៦៦ និង ៩៣ (ង)។

៦៧. បើទោះជាកម្ពុជានៅតែបន្តបង្ហាញនូវកំណើនសេដ្ឋកិច្ចរឹងមាំក្តី ក៏វិស័យទេសចរណ៍ និងវិស័យវាយនភណ្ឌកាត់ដេរ ត្រូវបានរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយការរាតត្បាតនៃជំងឺកូវីដ-១៩។ ធនាគារអភិវឌ្ឍន៍អាស៊ី បានវាយតម្លៃថានឹងមានការធ្លាក់ចុះនៃកំណើនសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០២០។[62] ធនាគារពិភពលោកបានព្រមានផងដែរពីស្ថានភាពសេដ្ឋកិច្ចនឹងមានភាពវឹកវរចលាចលនៅថ្ងៃខាងមុខសម្រាប់ប្រទេសកម្ពុជា និងបណ្តាប្រទេសដទៃផ្សេងទៀតនៅក្នុងតំបន់។[63] នេះមានផលវិបាកយ៉ាងច្បាស់សំរាប់ប្រជាជនកម្ពុជាជាច្រើន ជាពិសេស អ្នកដែលស្ថិតក្នុងចំណាត់ថ្នាក់ "ជិតក្រ" ដែលវិបត្តិសេដ្ឋកិច្ច អាចមានផលវិបាកធ្ងន់ធ្ងរដល់ពួកគេ និងគ្រួសារ ។

៦៨. អ្នករាយការណ៍ពិសេស បានទទួលព័ត៌មានពីក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជាថា ប្រទេសនេះ បាននិងកំពុងប្រឈមនឹងវិបត្តិសេដ្ឋកិច្ច ដែលកើតមានជាចម្បងដោយសារតម្រូវការខ្លាំង និងមិនមែនដោយសារភាពរអាក់រអួលនៃការផ្គត់ផ្គង់នោះទេ ដោយហេតុថា នៅក្នុងប្រទេសនេះ មិនមានការរីករាលដាលទ្រង់ទ្រាយធំនៃជំងឺកូវីដ-

---

59 របាយការណ៍លេខ A/HRC/42/60 កថាខណ្ឌទី១០ ។

60 របាយការណ៍លេខ A/HRC/42/60/Add.1 ។

61 របាយការណ៍លេខ A/HRC/42/60 កថាខណ្ឌទី៥៣ ។

62 គេហទំព័រ www.adb.org/countries/cambodia/economy

63 ក្រុមធនាគារពិភពលោក អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ក្នុងពេលកើតមានជំងឺកូវីដ-១៩ - បច្ចុប្បន្នភាពសេដ្ឋកិច្ចនៅអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ៖ខែមេសា ឆ្នាំ២០២០ (វ៉ាស៊ីនតោន ឌី ស៊ី : ធនាគារពិភពលោក) ។

១៩ ធំទេ ។ ការធ្លាក់ចុះនៃតម្រូវការក្នុងវិស័យវាយនភ័ណ្ឌ មានចន្លោះពី ៤០ ភាគរយទៅ ៦០ ភាគរយនៃទិន្នផល។ ចំនួនភ្ញៀវទេសចរណ៍អន្តរជាតិបានធ្លាក់ចុះប្រមាណជា ៩០ ភាគរយ។ វិស័យសំណង់ ដែលមានចំនួន ៤៤ ភាគរយនៃផលិតផលក្នុងស្រុកសរុប នៅតែមិនអាចព្យាករណ៍បាន ដោយសារមិនមានភាពប្រាកដប្រជានៅក្នុងតម្រូវការ ទោះបីជាទំនិញមួយចំនួនបានធ្លាក់ចុះប្រហែលជា ៤០ ភាគរយ ក៏ដោយ។

៦៩. អ្នករាយការណ៍ពិសេសបានទទួលការព្រួយបារម្ភជាញឹកញាប់លើបញ្ហាសិទ្ធិមនុស្ស ដែលកើតចេញពីមីក្រូឥណទាន មីក្រូហិរញ្ញវត្ថុ និងបំណុល។ កម្ពុជាមានបំណុលមីក្រូច្រើនបំផុតគិតជាអ្នកខ្ចីម្នាក់ៗនៅលើពិភពលោក ប្រហែល ៣៨០០ ដុល្លារ។[64] ប្រជាជនកម្ពុជាជាង ២,៦ លាននាក់ ត្រូវបានគេរាយការណ៍ថា បានទទួលប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុដែលមានតម្លៃសរុបជាង ១០ ពាន់កោដលានដុល្លារ។[65] តួលេខទាំងនេះមិនរាប់បញ្ចូលប្រាក់កម្ចីវាយរងក្រៅផ្លូវការទេ។[66] សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជាដែលតំណាងឱ្យអ្នកផ្តល់ប្រាក់កម្ចីចំនួនជាង ១០០ បានបញ្ជាក់ថា នៅក្នុងខែឧសភា ឆ្នាំ២០២០ មានអតិថិជនសរុប ១៩៦.៣០៧ នាក់ បានដាក់ពាក្យស្នើសុំរៀបចំរចនាសម្ព័ន្ធប្រាក់កម្ចីឡើងវិញ ដែលក្នុងនោះមាន ១៨០.៣០១ នាក់ ទទួលបានការយល់ព្រម។[67] កម្ចីនេះមានទឹកប្រាក់សរុបប្រមាណជា ៨១៧ លានដុល្លារ។ មូលហេតុនៃការរៀបចំរចនាសម្ព័ន្ធឡើងវិញ គឺទាក់ទងជាចម្បងទៅនឹងផលប៉ះពាល់នៃការរាតត្បាតនៃជំងឺកូវីដ-១៩ ទៅលើស្ថានភាពសេដ្ឋកិច្ចសង្គមនៃប្រជាជនកម្ពុជា។ មានការកត់សម្គាល់ថាការរៀបចំរចនាសម្ព័ន្ធប្រាក់កម្ចីបាននិងកំពុងកើតមានផងដែរនៅក្នុងធនាគារ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា។

៧០. អ្នករាយការណ៍ពិសេសមានការព្រួយបារម្ភថា សម្រាប់គ្រួសារជាច្រើន ការទូទាត់ប្រាក់កម្ចី ឥឡូវនេះ តំណាងឱ្យការគំរាមកំហែងដល់អនាគតការសន្សំ ហើយសូម្បីតែដីធ្លី

[64] Skylar Lindsay "ពលករកម្ពុជាជំពាក់បំណុលមីក្រូហិរញ្ញវត្ថុចំនួន ១០ ពាន់លានដុល្លារ នៅពេលកើតមានជំងឺកូវីដ-១៩ បាត់បង់ ប្រាក់ចំណូល" កាសែត ASEAN Today ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០ ។

Skylar Lindsay "ពលករកម្ពុជាជំពាក់បំណុលមីក្រូហិរញ្ញវត្ថុចំនួន ១០ ពាន់លានដុល្លារ នៅពេលកើតមានជំងឺកូវីដ-១៩ បាត់បង់ ប្រាក់ចំណូល" កាសែត ASEAN Today ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០ ។[66] យោងតាមរបាយការណ៍ថ្មីៗនេះដែលចេញដោយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកចំនួនពីរ កំណើនបំណុលមីក្រូហិរញ្ញវត្ថុ មានលើសពីប្រាក់ចំណូលនៅក្នុងប្រទេស។ អត្រានៃការជ្រៀតចូលនៃប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុនៅតាមខេត្តមួយចំនួនមាន ចំនួនលើសពី ៨០ ភាគរយនៃគ្រួសារ ហើយអ្នកខ្ចីប្រាក់ជាច្រើនបានយកប្រាក់កម្ចីបន្ថែមក្រៅផ្លូវការ ឬផ្លូវការដើម្បីសងម្ចាស់បំណុលផ្សេងទៀត។ (សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ)" ការធ្វើឱ្យខូចខាតទ្រព្យដាក់បញ្ចាំ៖ ការបាត់បង់ដីធ្លី និងការរំលោភបំពានក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា" ខែសីហា ឆ្នាំ ២០១៩) ។

[66] យោងតាមរបាយការណ៍ថ្មីៗនេះដែលចេញដោយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកចំនួនពីរ កំណើនបំណុលមីក្រូហិរញ្ញវត្ថុ មានលើសពីប្រាក់ចំណូលនៅក្នុងប្រទេស។ អត្រានៃការជ្រៀតចូលនៃប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុនៅតាមខេត្តមួយចំនួនមាន ចំនួនលើសពី ៨០ ភាគរយនៃគ្រួសារ ហើយអ្នកខ្ចីប្រាក់ជាច្រើនបានយកប្រាក់កម្ចីបន្ថែមក្រៅផ្លូវការ ឬផ្លូវការដើម្បីសងម្ចាស់បំណុលផ្សេងទៀត។ (សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ)" ការធ្វើឱ្យខូចខាតទ្រព្យដាក់បញ្ចាំ៖ ការបាត់បង់ដីធ្លី និងការរំលោភបំពានក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា" ខែសីហា ឆ្នាំ ២០១៩) ។

[67] ស៊ិន សារ៉ាត់ "មីក្រូហិរញ្ញវត្ថុ៖ ប្រាក់កម្ចី ៨១៧ លានដុល្លារ ត្រូវបានអនុម័តសម្រាប់ការរៀបចំរចនាសម្ព័ន្ធឡើងវិញ" កាសែតខ្មែរថាមស៍ ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២០ ។

របស់ពួកគេផង។ នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០ តំណាងសហគមន៍ចំនួន ១៤១ នៅទីក្រុង និងជនបទ បានដាក់ញត្តិទៅរដ្ឋាភិបាលដោយស្នើសុំឱ្យមានការកម្រិតផលប៉ះពាល់ដោយរាតត្បាតនៃជំងឺកូវីដ-១៩ លើសហគមន៍ក្រីក្រនៅទីក្រុង និងជនបទ រួមទាំងការបន្ធូរបន្ថយ ឬការព្យួរការសងបំណុលទៅស្ថាប័នមីក្រូហិរញ្ញវត្ថុ ធនាគារ និងម្ចាស់បំណុលឯកជនផងដែរ។ បំណុលមីក្រូហិរញ្ញវត្ថុបែបនេះ អាចធ្វើឱ្យប្រជាជនកម្ពុជាគ្មានដីធ្លី ដោយម្ចាស់បំណុលប្រើប្រាស់ដីជាទ្រព្យធានា។[68] ដីធ្លីមានសារៈសំខាន់ណាស់សម្រាប់ជីវភាព និងអត្តសញ្ញាណរបស់ប្រជាជនកម្ពុជា។ វាជាប្រភពចំណូល និងសន្តិសុខដ៏សំខាន់។ ដូចដែលគណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទបានកត់សម្គាល់នៅក្នុងសេចក្តីសន្និដ្ឋានចុងក្រោយរបស់ខ្លួន ក្នុងឆ្នាំ២០១៩ ថា ស្ត្រីនៅតាមជនបទប្រឈមនឹងបញ្ហាពិសេសជាមួយមីក្រូហិរញ្ញវត្ថុ។[69]

៧១. បន្ថែមទៅនឹងបញ្ហាប្រឈមចំពោះសេដ្ឋកិច្ច សហភាពអឺរ៉ុប បានបង្ហាញពីចេតនារបស់ខ្លួន ក្នុងការដកការចូលដោយសេរីសម្រាប់ទំនិញកម្ពុជាទៅកាន់ទីផ្សារសហគមន៍អឺរ៉ុប ដោយសារការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ និងមានលក្ខណៈជាប្រព័ន្ធ។ [70] រយៈពេលនៃការចូលរួមកាន់តែប្រសើរមុនការសម្រេចចិត្តរបស់គណៈកម្មការអឺរ៉ុប ដកការអនុគ្រោះពាណិជ្ជកម្មមួយចំនួន ដែលអនុញ្ញាតឱ្យមានការពិភាក្សារវាងរដ្ឋាភិបាល និងសហភាពអឺរ៉ុប។

៧២. ក្នុងនាមជាប្រទេសមួយនៅក្នុងប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច ប្រទេសកម្ពុជាទទួលបានការអនុគ្រោះបំផុតផ្នែកពាណិជ្ជកម្មពីសហភាពអឺរ៉ុប ក្រោមពន្ធ" អ្វីៗទាំងអស់លើកលែងតែអាវុធ" ដែលផ្តល់នូវកូតា និងការចូលដោយសេរីលើទីផ្សារតែមួយរបស់សហភាពអឺរ៉ុបសម្រាប់ទំនិញទាំងអស់ លើកលែងតែអាវុធ។ បច្ចុប្បន្ននេះ ប្រទេសកម្ពុជានាំចេញទំនិញដែលមានតម្លៃជាង ៥ ពាន់លានអឺរ៉ូ ក្នុងមួយឆ្នាំ ទៅកាន់សហភាពអឺរ៉ុបជាពិសេសពីវិស័យកាត់ដេររបស់ខ្លួន។ ស្ទើរតែមួយភាគប្រាំនៃការលក់ទាំងនោះ ត្រូវបានគ្រោងនឹងរងផលប៉ះពាល់ដោយការដកអនុគ្រោះពន្ធមួយផ្នែក ដែលគ្រោងនឹងចូលជាធរមាននៅខែសីហា ឆ្នាំ២០២០។[71]

---

68 លីកាដូ" ការធ្វើឱ្យខូចខាតទ្រព្យដាក់បញ្ចាំ៖ ការបាត់បង់ដីធ្លី និងការរំលោភបំពានក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា" ខែសីហា ឆ្នាំ ២០១៩) ។

69 របាយការណ៍លេខ CEDAW/C/KHM/CO/6 កថាខណ្ឌទី៤០ ។

70 គេហទំព័រ https://trade.ec.europa.eu/doclib/docs/2020/february/tradoc_158631.pdf ។

71 គណៈកម្មការអឺរ៉ុប ឯកសារ គ (២០២០) ៦៧៣ ចុងក្រោយ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០ ធ្វើវិសោធនកម្មឧបសម្ព័ន្ធទី ២ និងទី ៤ លើបទប្បញ្ញត្តិ (សហភាពអឺរ៉ុប) លេខ ៩៧៨/២០១២ ទាក់ទងនឹងការដកជាបណ្តោះអាសន្ននៃការរៀបចំដែលមានចែងក្នុងមាត្រា១ (២) នៃបទប្បញ្ញត្តិ (សហភាពអឺរ៉ុប) លេខ ៩៧៨/២០១២ ទាក់ទងនឹងផលិតផលមួយចំនួនដែលមានប្រភពដើមពីប្រទេសកម្ពុជា។ អាចរកបាននៅលើគេហទំព័រ https://ec.europa.eu/transparency/regdoc/rep/3/2020/EN/C-2020-673-F1-EN-MAIN-PART-1.PDF ។ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ ក្រុមប្រឹក្សាសហភាពអ៊ឺរ៉ុបបានបង្ហាញពីអចេតនាក្នុងការលើកជំទាស់ )https://data.consilium.europa.eu/doc/document/ST-6843-2020-REV-3/en/pdf) ។ សភាអ៊ឺរ៉ុបបានគាំទ្រផងដែរដល់ដំណើរការរបស់គណៈកម្មការអឺរ៉ុប ។

៧៣. ផលប៉ះពាល់លើវិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង មិនទាន់ត្រូវបានគេមើលឃើញថា នឹងមានការដកអនុគ្រោះផ្នែកពាណិជ្ជកម្មមួយចំនួនរបស់សហភាពអឺរ៉ុប គឺស្របពេលជាមួយនឹងការរីករាលដាលជាសកលនៃជំងឺកូវីដ-១៩ ។ ការឆ្លើយតបនឹងជំងឺរាតត្បាតនៅតាមបណ្តាប្រទេសគោលដៅនាំចេញរបស់កម្ពុជា រួមទាំងនៅអឺរ៉ុប មានភាពរហ័ស និងគួរឱ្យកត់សម្គាល់។ អាជីវកម្មនៅក្រៅប្រទេសជាច្រើន បានព្យាយាមដកខ្លួនចេញពីកិច្ចព្រមព្រៀងកិច្ចសន្យា ព្រោះថា វាយនភ័ណ្ឌមិនអាចត្រូវបានលក់ទៀតទេ។ អាជីវកម្មផ្សេងទៀត បានដកខ្លួនចេញពីការពិភាក្សាលើកិច្ចសន្យានាពេលអនាគត។ ពាណិជ្ជកម្មអន្តរជាតិស្ទើរតែបានបញ្ឈប់ ដោយសារតែការរឹតត្បិតការចូលក្នុងប្រទេស ហើយការផលិតវាយនភណ្ឌត្រូវបានជំនួសក្នុងករណីមួយចំនួន ដោយការផលិតឧបករណ៍ការពារផ្ទាល់ខ្លួន ដើម្បីឆ្លើយតបទៅនឹងតម្រូវការថ្មី។ វិស័យវាយនភណ្ឌកម្ពុជាពឹងផ្អែកលើការនាំចូល ដើម្បីផលិត និងផលិតការនាំចេញរបស់ខ្លួន។ ការរឹតត្បិតពាណិជ្ជកម្មអន្តរជាតិ និងការបង្អាក់ខ្សែសង្វាក់ផ្គត់ផ្គង់ បង្ហាញពីហានិភ័យដល់លទ្ធផលចុងក្រោយ។

៧៤. រដ្ឋាភិបាលបានដាក់ចេញកញ្ចប់ជំរុញសេដ្ឋកិច្ច ដើម្បីឆ្លើយតបទៅនឹងការកាត់បន្ថយការនាំចេញ និងទេសចរណ៍។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញសេចក្តីណែនាំលេខ ០៤៥/២០ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០[72] ដែលក្នុងនោះ បានលើកឡើងអំពីការព្យួរកិច្ចសន្យាការងារ និងការបង់វិភាគទានសម្រាប់បេឡាជាតិសន្តិសុខសង្គមសម្រាប់អ្នកដែលស្ថិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយការរាតត្បាតនៃជំងឺកូវីដ-១៩។ លើសពីនេះទៀត រដ្ឋាភិបាលនិងនិយោជកបានយល់ព្រមបែងចែកប្រាក់ឧបត្ថម្ភ ដែលបានបង់ទៅឱ្យនិយោជិកដែលកិច្ចសន្យាត្រូវបានផ្អាកជាបណ្តោះអាសន្ន។ ក្រសួងទេសចរណ៍ ក៏បានអនុវត្តការកាត់ពន្ធសម្រាប់សណ្ឋាគារ ផ្ទះសំណាក់ និងភោជនីយដ្ឋាន ដែលរងផលប៉ះពាល់ ពីដំបូងនៅខេត្តសៀមរាប ហើយបន្ទាប់មក តាមលិខិតលេខ ១១ ទៅក្រុង និងទីប្រជុំជនជាច្រើនទៀត។ រដ្ឋាភិបាល ត្រូវបានលើកទឹកចិត្តឱ្យធានាថា អាជីវកម្មដែលគាំទ្រទាំងអស់ ត្រូវគោរពតាមគោលការណ៍ណែនាំស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស។

៧៥. ជាសញ្ញាដំបូងនៃការផ្លាស់ប្តូរពីការឆ្លើយតបជាបន្ទាន់ទៅរកការងើបឡើងវិញ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ រដ្ឋាភិបាលបានចេញសារាចរមួយសម្រាប់ស្ថាប័នរដ្ឋនានាកាត់បន្ថយការចំណាយលើគ្រប់វិស័យក្នុងឆ្នាំ២០២១ ដើម្បីជួយសេដ្ឋកិច្ចឱ្យងើបឡើងវិញពីការរាតត្បាតនៃជំងឺកូវីដ-១៩។[73] បញ្ហានេះ ត្រូវបានជំរុញដោយតម្រូវការការប្រើប្រាស់ធនធានសាធារណៈដោយប្រយ័ត្នប្រយែង ដោយសារតែជំងឺរាតត្បាត។ នេះតំណាងឱ្យការធ្លាក់ចុះ ៥០ ភាគរយ ពីថវិការដ្ឋ ឆ្នាំ២០២០ ។ ខណៈដែលវិស័យមួយចំនួន ដូចជា

72 គេហទំព័រ https://ibccambodia.com/wp-content/uploads/2020/04/Instruction-045-on-Employment-Contract-and-NSSF-Payment-Suspension_EN.pdf.

73 គេហទំព័រ www.phnompenhpost.com/national/govt-implements-austerity-measures-assist-recovery

កសិកម្ម ឧស្សាហកម្ម និងសេវាកម្មនឹងឃើញមានកំណើនតិចតួច វិស័យផ្សេងទៀតរួមទាំង រដ្ឋបាលសាធារណៈ កិច្ចការសង្គម និងសេដ្ឋកិច្ច នឹងត្រូវកាត់បន្ថយ។ ផលប៉ះពាល់ខាងសិទ្ធិមនុស្សដែលអាចមាន ដោយការកាត់បន្ថយថវិកាបែបនេះ គួរតែត្រូវបានវាយតម្លៃមុនពេលអនុវត្ត។

៧៦. អ្នករាយការណ៍ពិសេស ជំរុញឱ្យរដ្ឋក្រើនរំលឹកដល់ធុរកិច្ចទាំងអស់ ដែលធ្វើជំនួញជាមួយកម្ពុជាអំពីទំនួលខុសត្រូវរបស់ខ្លួនទាក់ទងនឹងគោលការណ៍ណែនាំស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស[74] ជាពិសេស គោរពស្តង់ដារការងារអន្តរជាតិ និងសិទ្ធិរបស់និយោជិក និងអ្នកម៉ៅការ។ នេះរួមបញ្ចូលទាំងធុរកិច្ចទាំងឡាយគោរពកិច្ចសន្យាដែលបានព្រមព្រៀងស្តីពីការលក់ និងការផ្គត់ផ្គង់។

## V. អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

៧៧. ការងាររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងប្រទេសកម្ពុជា នៅតែបន្តមាន ៤ ករណីសកម្ម៖ ការប្តឹងឧទ្ធរណ៍ទៅអង្គជំនុំជម្រះតុលាការកំពូល អំពីការផ្តន្ទាទោស និងការកាត់ទោស ខៀវ សំផន (សំណុំរឿង ០០២/២) និងដំណើរការនីតិវិធីបណ្តោះអាសន្ននៅក្នុងសំណុំរឿងប្រឆាំងនឹង មាស មុត (ករណី ០០៣) យឹម ទិត្យ (ករណី ០០៤) និង អៅ អាន (សំណុំរឿង ០០៤/២)

៧៨. ទាក់ទងនឹងសំណុំរឿង០០២/២ បណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ដែលបច្ចុប្បន្នស្ថិតនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។[75] សហជនជាប់ចោទរបស់គាត់ គឺ នួន ជា បានទទួលមរណភាពនៅខែសីហា ឆ្នាំ២០១៩ ដូច្នេះហើយ នីតិវិធីប្រឆាំងនឹងលោក ជា ត្រូវបានបញ្ចប់។

៧៩. ករណីបុរេជំនុំជម្រះទាំង ៣ ស្ថិតក្នុងស្ថានភាពមានបញ្ហា។ នៅក្នុងឧទាហរណ៍នីមួយៗ សហចៅក្រមស៊ើបអង្កេតទាំងពីរ បានចេញដីកាដាច់ដោយឡែក និងដោយលក្ខណៈផ្ទុយគ្នាស្រឡះ សហចៅក្រមស៊ើបអង្កេតជាតិ បានច្រានចោលការចោទប្រកាន់នេះ ខណៈដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចោទប្រកាន់ជនជាប់ចោទ។ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការសម្រេចចិត្តទាំងនេះ ត្រូវបានប្តឹងនៅក្នុងករណីនីមួយៗ។

៨០. ក្នុងករណី ០០៤/២ ប្រឆាំងនឹង អោ អាន អង្គបុរេជំនុំជម្រះបានបើកសវនាការចំនួនបីថ្ងៃនៅខែមិថុនា ឆ្នាំ២០១៩ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយទាំងពីរ។ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះបានចេញសេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ដែលមានចៅក្រមទាំងអស់យល់ស្របថា ការចេញដីកាដំណោះស្រាយផ្ទុយគ្នាចំនួន២ គឺខុសច្បាប់។[76] បន្ទាប់មកអង្គជំនុំជម្រះត្រូវបាន

---

74 គេហទំព័រ www.ohchr.org/EN/NewsEvents/Pages/DisplayNews.aspx?NewsID=25837&LangID=E

75 គេហទំព័រ www.eccc.gov.kh/en/case/topic/1298

76 គេហទំព័រ https://eccc.gov.kh/sites/default/files/documents/courtdoc/%5Bdate-in-tz%5D/D363_3_EN.PDF ។ សូមមើលផងដែរ នូវសេចក្តីអធិប្បាយរបស់រដ្ឋាភិបាលទាក់ទងនឹងកថាខណ្ឌទី៨០ ។

បំបែក ទៅតាមយថាហេតុច្បាប់។ ចៅក្រមជាតិទាំង ៣ រូប អាចបានច្រានចោលករណីនេះ ខណៈដែលចៅក្រមអន្តរជាតិទាំងពីររូបនឹងបញ្ជូនរឿងក្តីនេះទៅជំនុំជម្រះ។ មិនមានជំហាណាមួយដែលទទួលបាន "ចំនួនច្រើនលើសលុប" ដែលចាំបាច់សម្រាប់ចៅក្រមជាតិ និងអន្តរជាតិឡើយ។[77] ចាប់តាំងពីពេលនោះមក ដោយសារទស្សនៈផ្ទុយគ្នាអំពីស្ថានភាពនៃសំណុំរឿងក្តី សំណុំរឿងនេះមិនត្រូវបានផ្ទេរជាផ្លូវការទៅអង្គជំនុំជម្រះសាលាដំបូងដែលបានបដិសេធផងដែរមិនចាត់ការតាមផ្លូវតុលាការលើស្ថានភាពនៃករណីនេះ ដោយកត់សម្គាល់ថាមិនអាចធ្វើបាន។ ជាលទ្ធផល សហព្រះរាជអាជ្ញាអន្តរជាតិកំពុងប្តឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល ដោយលើកហេតុផលថា ករណីនេះត្រូវបានបញ្ចប់ទាំងស្រុង ដោយសាររំលោភលើក្របខ័ណ្ឌច្បាប់ជាធរមាន។[78]

៨១. ការវិវត្តន៍នៃសំណុំរឿង ០០៤/២ និងការជាប់ពាក់ព័ន្ធនៃករណីនេះជាមួយករណីផ្សេងទៀត ដែលកំពុងស្ថិតក្នុងដំណាក់កាលបុរេជំនុំជម្រះនៅឡើយ គឺមានការព្រួយបារម្ភយ៉ាងខ្លាំង។ ក្របខ័ណ្ឌច្បាប់នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបង្ហាញយ៉ាងច្បាស់ថា បើគ្មានកិច្ចព្រមព្រៀងភ្ជាប់កាតព្វកិច្ច ដើម្បីបញ្ឈប់ជំហ៊ានបន្តទៀតក្នុងដំណើរការនីតិវិធីទេ ការសន្មតជាបឋមគឺសម្រាប់ដំណើរការនីតិវិធីបន្ត។ ទោះជាយ៉ាងណាក៏ដោយ ក្នុងករណីបច្ចុប្បន្ននេះ ឥទ្ធិពលជាក់ស្តែងនៃទស្សនៈផ្ទុយគ្នារវាងសមាសធាតុតុលាការ និងរដ្ឋបាលតុលាការជាតិ និងអន្តរជាតិ គឺត្រូវទុកឱ្យដំណើរការនីតិវិធីផ្អាកដំណើរការ ក្នុងស្ថានភាពមិនប្រាកដប្រជាផ្នែកច្បាប់។ ស្ថានភាពបែបនេះ ប្រសិនបើវានៅតែបន្ត គឺមិនអាចទទួលយកបានពីទស្សនៈទាននៃនីតិរដ្ឋ និងការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌មួយរឹងមាំ។ វាក៏ជាបញ្ហាប្រឈមផងដែរ សម្រាប់ជនរងគ្រោះនៃរបបខ្មែរក្រហម ដែលមានសេចក្តីក្លាហានយ៉ាងខ្លាំង បានស្វែងរកសិទ្ធិទទួលបានយុត្តិធម៌ ដែលបានសន្យាដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចំពោះមហាឧក្រិដ្ឋកម្មអន្តរជាតិទាំងនេះ។ អ្នករាយការណ៍ពិសេសនឹងបន្តតាមដានយ៉ាងដិតដល់នូវនីតិវិធីបន្តទៀត ក្នុងករណីទាំងនេះ។

## VI. ការចូលរួមរបស់ប្រទេសកម្ពុជាជាមួយយន្តការសិទ្ធិមនុស្ស

៨២. អ្នករាយការណ៍ពិសេស ស្វាគមន៍ការចូលរួមរបស់កម្ពុជា ក្នុងការឃ្លាំមើល និងយន្តការត្រួតពិនិត្យជាអន្តរជាតិមួយចំនួនទាក់ទងនឹងសិទ្ធិមនុស្ស និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ រដ្ឋាភិបាលបានចូលរួមដោយស្ម័គ្រចិត្ត នៅក្នុងវេទិកានយោបាយជាន់ខ្ពស់ស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព ដែលបានរៀបចំឡើងនៅទីក្រុងញូវយ៉កក្នុង

77 ការឆ្លើយបញ្ជាក់ថាពិតរបស់ចៅក្រមបួនរូប ក្នុងចំណោមចៅក្រមប្រាំរូប។ សូមមើលមាត្រា២៣ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។

78 គេហទំព័រ www.eccc.gov.kh/en/articles/press-release-international-co-prosecutor-and-national-co-prosecutor

ខែកក្កដា ឆ្នាំ២០១៩[79] ដោយរាយការណ៍អំពីការធ្វើមូលដ្ឋានីយកម្មនៃគោលដៅ និងអំពីវឌ្ឍនភាពដែលសម្រេចបាន និងបញ្ហាប្រឈមផ្សេងៗ។ ក្រុមប្រឹក្សាសិទ្ធិមនុស្សបានបញ្ចប់ជុំទី៣ របស់ប្រទេសកម្ពុជា នៃការពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់ នៅខែកក្កដា ឆ្នាំ២០១៩ ជាមួយនឹងការអនុម័តសេចក្តីសំរេចលេខ ៤១/១១៤ ស្តីពីលទ្ធផលនៃការពិនិត្យ[80] ដោយកត់សម្គាល់ថា ប្រទេសកម្ពុជាបានគាំទ្រនូវអនុសាសន៍ចំនួន ១៧៣ ដែលទទួលបានក្នុងអំឡុងពេលពិនិត្យ ដែលធ្វើឡើងដោយក្រុមការងារទទួលបន្ទុកការពិនិត្យ ជាសកលតាមកាលកំណត់នៅខែមករា ឆ្នាំ២០១៩។[81] អនុសាសន៍ទាំងនេះភាគច្រើនបញ្ជាក់ជាថ្មីនូវអនុសាសន៍ទាំងឡាយ ដែលអ្នករាយការណ៍ពិសេសមួយចំនួនបានផ្តល់កាលពីពេលកន្លងមក។ អ្នករាយការណ៍ពិសេស មានសេចក្តីរីករាយដែលបានទទួលការគាំទ្រជាផ្លូវការពីរដ្ឋាភិបាល តាមរយៈដំណើរការពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់។ ទន្ទឹមនឹងអនុសាសន៍ដែលបានគាំទ្រទាំងនេះ គ្របដណ្តប់លើសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានជាច្រើនក្តី ក៏គួរឱ្យកត់សម្គាល់ដែលថា ៤១ ភាគរយ[82] ក្នុងចំណោមនោះ ផ្តោតលើគោលដៅទី១៦ ស្តីពីសន្តិភាព យុត្តិធម៌ និងស្ថាប័នរឹងមាំ ដែលជាប្រធានបទផ្តោតសំខាន់នៃបេសកកម្មរបស់អ្នករាយការណ៍ពិសេស នៅឆ្នាំ ២០១៨ ដល់ ឆ្នាំ២០១៩ ។[83]

៨៣. អ្នករាយការណ៍ពិសេស ស្វាគមន៍សិក្ខាសាលាផ្សព្វផ្សាយ ស្តីពីអនុសាសន៍ពិនិត្យជាសកលតាមកាលកំណត់ ដែលបានរៀបចំរួមគ្នាដោយគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ការិយាល័យ OHCHR ការិយាល័យអ្នកសម្របសម្រួលនៃអង្គការសហប្រជាជាតិ និងយូភីអា អ៊ីនហ្វូ ដែលជាអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ក្នុងខែតុលា ឆ្នាំ២០១៩។ រដ្ឋាភិបាលគួរបន្តការងាររបស់ខ្លួន ឈានទៅរកផែនការអនុវត្តការត្រួតពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់ និងចូលរួមក្នុងការពិនិត្យពិគ្រោះយោបល់ប្រចាំឆ្នាំ អំពីវឌ្ឍនភាពដែលបានសម្រេចបាន ក្នុងការអនុវត្តដែលមានការចូលរួមពីក្រសួងពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល។

៨៤. នៅក្នុងអំឡុងពេលរបាយការណ៍ រដ្ឋាភិបាលបានចូលរួមក្នុងការពិនិត្យរបស់ស្ថាប័នសន្ធិសញ្ញាចំនួន២ គឺគណៈកម្មាធិការលុបបំបាត់ការរើសអើងលើស្ត្រីភេទ[84] ក្នុងខែតុលា ឆ្នាំ២០១៩ និងគណៈកម្មាធិការលុបបំបាត់ការរើសអើងពូជសាសន៍[85] ក្នុងខែវិច្ឆិកាឆ្នាំ ២០១៩ ។

79 ឯកសារមាននៅលើគេហទំព័រ https://s Sustainableevelopment.un.org/memberstates/cambodia
80 សូមមើលផងដែរ របាយការណ៍ A/HRC/41/17 និងសេចក្តីបន្ថែម ១។
81 របាយការណ៍ A/HRC/41/17/សេចក្តីបន្ថែម ១
82 គេហទំព័រ https://lib.ohchr.org/HRBodies/UPR/Documents/Session32/KH/Infographic_Cambodia.pdf
83 របាយការណ៍ A/HRC/42/60
84 របាយការណ៍ CEDAW/C/KHM/CO/6
85 របាយការណ៍ CERD/C/KHM/CO/14-17

៨៥. នៅថ្ងៃទី២ ខែមេសា ឆ្នាំ២០១៩ កម្ពុជាបានបញ្ជូនរបាយការណ៍តាមកាលកំណត់លើកទី៣ របស់ខ្លួន ទៅគណៈកម្មាធិការសិទ្ធិមនុស្ស។[86] របាយការណ៍តាមកាលកំណត់រួមបញ្ចូលគ្នាលើកទី៤ ដល់លើកទី ៦ របស់ខ្លួន[87] ទៅគណៈកម្មាធិការសិទ្ធិកុមារត្រូវបានគ្រោងពិនិត្យនៅឆ្នាំ២០២០ ។ រដ្ឋាភិបាល បានដាក់បញ្ជូនរបាយការណ៍របស់ខ្លួនផងដែរទៅគណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្នុងខែមិថុនា ឆ្នាំ២០២០។[88] កាលបរិច្ឆេទនៃសម័យប្រជុំរបស់ស្ថាប័នសន្ធិសញ្ញានៅមិនទាន់បញ្ជាក់នៅឡើយ ដោយសារតែការរឹតត្បិតការធ្វើដំណើរនៅក្នុងអំឡុងពេលមានការរីករាលដាននៃជំងឺកូវីដ-១៩ ។ អ្នករាយការណ៍ពិសេស លើកទឹកចិត្តរដ្ឋាភិបាលឱ្យចូលរួមយ៉ាងសកម្មក្នុងដំណើរការឃ្លាំមើលការអនុវត្តសន្ធិសញ្ញា ដាក់បញ្ជូនរាល់របាយការណ៍ដែលហួសកាលកំណត់ និងរៀបចំផែនការបញ្ជូនរបាយការណ៍ឱ្យបានទាន់ពេលវេលានៅថ្ងៃអនាគត។

៨៦. ជាអកុសល ទោះបីជាមានការធានា[89] ក៏ដោយ ក៏រដ្ឋាភិបាលមិនបានដាក់បញ្ជូនឯកសារស្នូលរួមដែលបានធ្វើបច្ចុប្បន្នភាពឡើយ។ អ្នករាយការណ៍ពិសេស គុសបញ្ជាក់ឡើងវិញនូវការអំពាវនាវរបស់អ្នកស្រី សូមឱ្យធ្វើបច្ចុប្បន្នភាពឯកសារស្នូលរួម។ ឯកសារស្នូលបច្ចុប្បន្នមានកាលបរិច្ឆេទឆ្នាំ១៩៩៧ ហើយបច្ចុប្បន្ននេះ ប្រទេសកម្ពុជាជាប្រទេសមួយដែលខុសគ្នាពីមុនឆ្ងាយណាស់ ដែលមានការរីកចម្រើនគួរឱ្យកត់សម្គាល់ចាប់តាំងពីដើមសម័យយុគសម័យរដ្ឋធម្មនុញ្ញ។ ឯកសារស្នូលរួមត្រឹមត្រូវមួយ នឹងធ្វើឱ្យការងាររបស់រដ្ឋមានភាពល្អប្រសើរ នៅពេលរៀបចំរបាយការណ៍តាមកាលកំណត់របស់ខ្លួន។

៨៧. ដំណើរការពិនិត្យរបស់ស្ថាប័នសន្ធិសញ្ញាតំណាងឱ្យឱកាសសម្រាប់រដ្ឋាភិបាល ចូលរួមក្នុងការពិភាក្សាក្នុងន័យស្ថាបនាជាមួយអ្នកជំនាញឯករាជ្យផ្សេងៗ ស្តីពីវឌ្ឍនភាពដែលសម្រេចបាន និងបញ្ហាប្រឈមដែលបានជួបប្រទះ ក្នុងការធ្វើឱ្យសម្រេចបាននូវកាតព្វកិច្ចសន្ធិសញ្ញារបស់កម្ពុជា។ បន្ទាប់ពីការពិនិត្យនីមួយៗ ការសេចក្តីសន្និដ្ឋានចុងក្រោយ គួរតែត្រូវបានបកប្រែជាភាសាខ្មែរ ផ្សព្វផ្សាយ និងពិភាក្សាជាសាធារណៈនៅក្នុងប្រទេស។ នេះគួរតែត្រូវបានអមដោយការពិភាក្សាដែលមានលក្ខណៈទូលំទូលាយ និងបរិយាបន្នជាមួយគ្រប់ភាគីពាក់ព័ន្ធដែលអាចជួយក្នុងការអនុវត្តអនុសាសន៍ដែលបានធ្វើឡើង ក៏ដូចជារួមចំណែកក្នុងការតាមដាន[90] និងធ្វើរបាយការណ៍ជាបន្តបន្ទាប់។

៨៨. របាយការណ៍ដំបូងរបស់កម្ពុជាទៅគណៈកម្មាធិការសិទ្ធិជនពិការ និងទៅគណៈកម្មាធិការទទួលបន្ទុកការបាត់ខ្លួនដោយបង្ខំ ដែលរបាយការណ៍ទាំងពីរនេះ បានដល់កាលកំណត់ក្នុងឆ្នាំ២០១៥ នៅមិនទាន់បានបញ្ជូននៅឡើយ។ លើសពីនេះទៀត ការឆ្លើយតបទៅនឹងបញ្ជីបញ្ហាសម្រាប់អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬ

86 របាយការណ៍ CCPR/C/KHM/3

87 របាយការណ៍ CRC/C/KHM/4-6

88 របាយការណ៍ E/C.12/KHM/2

89 របាយការណ៍ A/HRC/42/60 កថាខណ្ឌទី១១

90 សូមមើល ឧទា. របាយការណ៍ ស៊ី ដ /C/KHM/CO/6 កថាខណ្ឌទី៥៥ ស្នើសុំឲ្យអនុវត្តបន្តក្នុងរយៈពេល ២ ឆ្នាំ។

ទណ្ឌកម្មដទៃទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ក៏ត្រូវបានហួសកាលកំណត់ផងដែរចាប់តាំងពីឆ្នាំ២០១៤ មក។ ការខកខានមិនបានបញ្ជូនការឆ្លើយតបទៅនឹងបញ្ជីបញ្ហាទំនងជាបណ្ដាលមកពីការចាត់តាំងភារកិច្ចទៅឱ្យគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម ដែលជាយន្តការថ្នាក់ជាតិ សម្រាប់បង្ការការធ្វើទារុណកម្ម តាមរយៈព្រះរាជក្រឹត្យ។ យន្តការឯករាជ្យមួយនេះ មិនគួរត្រូវបានប្រគល់ភារកិច្ចឱ្យធ្វើរបាយការណ៍ក្នុងនាមរដ្ឋឡើយ។ ការបញ្ចប់របាយការណ៍ហួសកាលកំណត់ ផ្ដល់ឱ្យរដ្ឋនូវឱកាសមួយ ដើម្បីឆ្លុះបញ្ចាំងពីវឌ្ឍនភាពដែលបានធ្វើ និងដើម្បីកំណត់ឱកាស ដើម្បីបញ្ចូលកាន់តែប្រសើរឡើងថែមទៀត នូវសិទ្ធិសេរីភាពដែលអាចពឹងអាស្រ័យគ្នា និងដែលអាចទាក់ទងបាន និងមិនអាចកាត់ផ្ដាច់បាន សម្រាប់ប្រជាជនកម្ពុជាទាំងគ្រប់រូប ក្នុងការបំពេញកាតព្វកិច្ចដែលមានចែងក្នុងសន្ធិសញ្ញានេះ។

៨៩. ដោយការចូលរួមបានកើនឡើងនៅទូទាំងយន្តការឃ្លាំមើលសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ នេះគឺជាពេលវេលាដ៏ល្អមួយសម្រាប់ប្រទេសកម្ពុជា ក្នុងការពិចារណារៀបចំផែនការសកម្មភាពជាតិសម្រាប់សិទ្ធិមនុស្ស ដោយយកគំរូតាមប្រទេសដទៃទៀតនៅក្នុងតំបន់។ នេះអាចរាប់បញ្ចូលកាលវិភាគបន្តសម្រាប់ស្ថាប័នសន្ធិសញ្ញា និងរបាយការណ៍ពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់ ការធ្វើបច្ចុប្បន្នភាពពាក់កណ្ដាលអាណត្តិ និងការអនុវត្តមូលដ្ឋានទិន្នន័យតាមដានអនុសាសន៍ជាតិស្ដីពីសិទ្ធិមនុស្ស។ នេះគួរតែរួមបញ្ចូលការងារធ្វើបច្ចុប្បន្នភាព ស្ដីពីការធ្វើឱ្យសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ម៉្យាងវិញទៀត កម្ពុជាគួរតែពង្រឹងវិមាត្រសិទ្ធិមនុស្សនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រដ្ឋាភិបាល សំដៅជួយឱ្យរដ្ឋាភិបាលឆ្លុះបញ្ចាំងពីមធ្យោបាយដែលល្អបំផុត ក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្សទាំងអស់នៅក្នុងប្រទេស។ ផែនការសកម្មភាពជាតិ ក៏នឹងផ្ដល់នូវក្របខ័ណ្ឌសម្រាប់ការចូលរួមក្នុងន័យស្ថាបនាជាមួយអ្នកពាក់ព័ន្ធជាច្រើន រួមទាំងអង្គការសង្គមស៊ីវិលផងដែរ។ ការចូលរួមបែបនេះ គឺចាំបាច់សម្រាប់ការធានាដល់ការអនុវត្តនូវអនុសាសន៍ដែលបានទទួលយក និងសេចក្ដីសន្និដ្ឋានចុងក្រោយ។

## VII. ឧបាស្រ័យទៅរដ្ឋាភិបាល

៩០. ក្នុងកំឡុងពេលធ្វើរបាយការណ៍ អ្នករាយការណ៍ពិសេស រួមជាមួយអ្នកកាន់អាណត្តិដទៃទៀត បានចេញឧបាស្រ័យទៅរដ្ឋាភិបាលកម្ពុជា។ ឧបាស្រ័យទាំងនេះ ត្រូវបានរាយការណ៍ទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស។[91] រាល់ឧបាស្រ័យសាធារណៈទាំងអស់ ក៏មាននៅលើគេហទំព័រឧបាស្រ័យរបស់នីតិវិធីពិសេសនៃការិយាល័យ OHCHR ផងដែរ។[92] រាល់ការឆ្លើយតបដែលរដ្ឋាភិបាលបានដាក់បញ្ជូនក៏មានផងដែរ។ អ្នករាយការណ៍ពិសេសស្វាគមន៍ចំពោះការដែលថា រដ្ឋាភិបាលបានឆ្លើយតបទៅនឹងឧបាស្រ័យមួយចំនួន។

[91] សូមមើលរបាយការណ៍ A/HRC/44/59, A/HRC/43/77, A/HRC/42/65 និង A/HRC/41/56

[92] គេហទំព័រ https://spcommreports.ohchr.org/

ទោះជាយ៉ាងណាក៏ដោយ អ្នកស្រីមិនទាន់ពេញចិត្តនៅឡើយទេ ដែលរដ្ឋាភិបាលមិនបានចាត់វិធានការគ្រប់គ្រាន់ ដើម្បីដោះស្រាយ ហើយក្នុងករណីចាំបាច់ កែតម្រូវបញ្ហាទាំងឡាយដែលបានលើកឡើង។

## VIII. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

៩១. អ្នករាយការណ៍ពិសេសនៅតែប្តេជ្ញាចិត្តគាំទ្រដល់ការសន្ទនាគ្នា និងដំណើរការធ្វើសេចក្តីសម្រេចចិត្តដែលមានការចូលរួម ទន្ទឹមនឹងអ្នកស្រីបន្តតាមដាន និងតស៊ូមតិ ដើម្បីទទួលបានយ៉ាងពេញលេញនូវសិទ្ធិមនុស្ស ដោយមនុស្សគ្រប់រូបនៅកម្ពុជា។ ដូចដែលបានកត់សម្គាល់នៅក្នុងរបាយការណ៍នេះ ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជានៅតែគ្របដណ្តប់ដោយការរឹតត្បិតសេរីភាពជាមូលដ្ឋាន និងសិទ្ធិនយោបាយ ដោយមានការកើនឡើងនៃការចាប់ខ្លួន និងការឃុំខ្លួនសមាជិក និងអ្នកគាំទ្រអតីតគណបក្សសង្គ្រោះជាតិ។ លំហពលរដ្ឋបានបន្តធ្លាក់ចុះ ដោយសារអ្នកការពារសិទ្ធិមនុស្ស អង្គការសង្គមស៊ីវិល និងអ្នកដែលប្រើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ត្រូវបានទទួលរងនូវការបំភិតបំភ័យ និងការចាប់ខ្លួន។

៩២. ការរាតត្បាតនៃជំងឺកូវីដ-១៩ និងផលប៉ះពាល់សេដ្ឋកិច្ចជាលទ្ធផល កំពុងតែប៉ះពាល់យ៉ាងខ្លាំងទៅលើសិទ្ធិមនុស្សជាទូទៅ។ ការឆ្លើយតបផ្នែកសេដ្ឋកិច្ច សង្គម របស់រដ្ឋាភិបាល គួរតែដោះស្រាយនូវវិសមភាព និងទុក្ខសោក និងមានគោលបំណងលើកកំពស់សិទ្ធិមនុស្សសម្រាប់ប្រជាជនកម្ពុជាគ្រប់រូប។ ដោយរំលឹកឡើងវិញនូវក្របខណ្ឌ Sendai សម្រាប់ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយឆ្នាំ២០១៥–២០៣០ ដោយ "កសាងឱ្យប្រសើរឡើងវិញ"[93] រដ្ឋាភិបាលអាចធានាថា គ្មាននរណាម្នាក់ត្រូវបានគេទុកចោលឡើយ។ ដើម្បីសំរេចគោលដៅនេះ រដ្ឋាភិបាលក៏គួរតែគ្រើនរំលឹកដល់ការធ្វើជំនួញជាមួយប្រទេសកម្ពុជាអំពីការទទួលខុសត្រូវរបស់ពួកគេ ទាក់ទងនឹងគោលការណ៍ណែនាំស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស រួមទាំងការគោរពកិច្ចសន្យាដែលបានព្រមព្រៀងគ្នា ស្តីពីការលក់ និងការផ្គត់ផ្គង់ និងធានាថា អាជីវកម្មដែលទទួលបានអត្ថប្រយោជន៍ពីវិធានការជំរុញសេដ្ឋកិច្ច ក៏ត្រូវបំពេញតាមស្តង់ដារដែលមាននៅក្នុងគោលការណ៍នេះផងដែរ។

៩៣. អ្នករាយការណ៍ពិសេស ផ្តល់អនុសាសន៍ដល់រដ្ឋាភិបាលកម្ពុជា៖

(ក) ជម្រុញឱ្យមានកិច្ចពិភាក្សាជាមួយគ្រប់ភាគី និងស្វែងរកការសន្ទនាក្នុងបរិយាកាសមួយប្រកបដោយសន្តិវិធី ដែលអនុញ្ញាតឱ្យមានការបញ្ចេញមតិនយោបាយផ្ទុយគ្នា និងចៀសវាងការរឹតត្បិតបន្ថែមលើសេរីភាពជាមូលដ្ឋានលើសពីការចាំបាច់សម្រាប់ការទទួលបានការគោរពសិទ្ធិមនុស្សពីគ្រប់មជ្ឈដ្ឋាន។

[93] សេចក្តីសម្រេចរបស់មហាសន្និបាតលេខ ៦៩/២៨៣ ឧបសម្ព័ន្ធ ១ ។

(ខ) បន្តអន្តរកម្ម និងពិគ្រោះយោបល់ជាវិជ្ជមានរបស់ខ្លួន ជាមួយអង្គការសង្គមស៊ីវិល។ ការពិគ្រោះយោបល់គួរតែមានជាដំកំភួនសា និងជួយកសាងសង្គមមួយប្រកបដោយបរិយាបន្នច្រើនជាងមុន តាមរយៈការចូលរួមប្រកបដោយអត្ថន័យ។

(គ) ពង្រឹងការការពារមិនឱ្យមានការយាយី ការគំរាមកំហែង និងការបំភិតបំភ័យអ្នកការពារសិទ្ធិមនុស្ស អ្នកសារព័ត៌មាន និងសមាជិកសង្គមស៊ីវិល។

(ឃ) ការកែទំរង់ស្ថាប័ននៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ និងធានាថារាល់កិច្ចខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយភាពចង្អៀតណែននៃពន្ធនាគារ និងធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌនៃការឃុំខ្លួន រួមទាំងតាមរយៈការពន្លឿនការជំនុំជម្រះ គឺត្រូវអនុលោមតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ។ នេះរួមបញ្ចូលទាំងការដាក់ឱ្យអនុវត្តការឃុំខ្លួនបណ្តោះអាសន្ន តែក្នុងករណីចាំបាច់បំផុត ស្របតាមច្បាប់ និងពិចារណាលើការតាក់តែងគោលការណ៍ណែនាំថ្មីស្តីពីស្តង់ដារ និងតម្រូវការផ្នែកភស្តុតាង។

(ង) ធានាឱ្យមានដំណើរការពិគ្រោះយោបល់មួយប្រកបដោយតម្លាភាព ដើម្បីពិនិត្យឡើងវិញនូវច្បាប់ស្តីពីការបោះឆ្នោត និងគណបក្សនយោបាយ ច្បាប់ស្តីពីសហជីពកម្មករ ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក៏ដូចជាសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មានដែលបានឆ្លងកាត់ដំណើរការពិគ្រោះយោបល់បន្ថែមទៀត ដើម្បីធានាថាច្បាប់ទាំងនេះ ស្របតាមតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់កម្ពុជា និងរៀបចំតាក់តែងផែនទីបង្ហាញផ្លូវសម្រាប់ជំហានបន្ទាប់ នៅពេលចូលរួមក្នុងការតាក់តែងច្បាប់ និងការធ្វើវិសោធនកម្មច្បាប់ និងផ្តល់ជាភាសាពង្រាង ដើម្បីធានាថាអ្នកពាក់ព័ន្ធទាំងអស់អាចចូលរួមជាដំកំភួននៅក្នុងដំណើរការធ្វើវិសោធនកម្ម

(ច) ពិចារណាលើការអនុម័តច្បាប់មួយដែលមានលក្ខណៈទូលំទូលាយ មិនរើសអើងដែលមានវិសាលភាពលើការរើសអើងគ្រប់ប្រភេទ រួមមានការរើសអើងដោយផ្ទាល់ និងដោយប្រយោល ហើយធានាថាច្បាប់នេះឆ្លុះបញ្ចាំងពីការពិតនៃពហុវិស័យនៃការរើសអើង។ គួរតែរៀបចំតាក់តែង និងផ្សព្វផ្សាយគោលការណ៍ណែនាំសមស្រប ដើម្បីគាំទ្រដល់ការអនុវត្តច្បាប់នេះ។

(ឆ) ពិនិត្យក្របខ័ណ្ឌច្បាប់ដែលគ្រប់គ្រងមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាគ្រឿងញៀន ដើម្បីបង្កើតឱ្យមានអភិបាលកិច្ចច្បាស់លាស់ និងរចនាសម្ព័ន្ធគណនេយ្យភាព ពិចារណាលើការធ្វើវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងគ្រឿងញៀន ដើម្បីហាមឃាត់ការស្តារនីតិសម្បទាគ្រឿងញៀនជាកំហិត អនុញ្ញាតតែនៅពេលដែលមានការយល់ព្រមពីចៅក្រម ហើយក្នុងករណីដែលគ្មានជម្រើសផ្សេងក្រៅពីការឃុំខ្លួន និងពង្រឹង និងលើកកម្ពស់ការព្យាបាល និងស្តារនីតិសម្បទាតាមសហគមន៍ប្រកបដោយប្រសិទ្ធភាព ការយល់ព្រម និងតាមគោលការណ៍ស្ម័គ្រចិត្ត។

(ជ) សម្រួលនីតិវិធីក្នុងការចេញប័ណ្ណកម្មសិទ្ធិដីសហគមន៍ អនុញ្ញាតឱ្យជនជាតិដើមភាគតិចទទួលបានការទទួលស្គាល់ និងទាមទារដីធ្លីរបស់ពួកគេ និងការពារជនជាតិដើមភាគ

តិចពីការវាយប្រហារ និងការបំភិតបំភ័យពីសំណាក់ភ្នាក់ងាររដ្ឋាភិបាល និងក្រុមហ៊ុនឯកជនផ្សេងៗ នៅពេលដែលពួកគេព្យាយាមអនុវត្តសិទ្ធិទាក់ទងនឹងដីសហគមន៍របស់ខ្លួន

(ឈ) ផ្តល់ការណែនាំដល់អាជ្ញាធរមូលដ្ឋានស្តីពីការអនុវត្តសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃស្តីពីការចេញឯកសាររដ្ឋបាល និងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ដល់ប្តីប្រពន្ធ និងលិខិតបញ្ជាក់កំណើតដល់កូនខ្មែរ និងជនចំណាកស្រុកបរទេស ដោយធានាថាសេចក្តីណែនាំរបស់ក្រសួង ត្រូវបានអនុវត្តយ៉ាងពេញលេញនៅទូទាំងប្រទេស។

(ញ) វាយតម្លៃបទពិសោធរបស់ខ្លួន ក្នុងកំឡុងពេលដែលមានការរាលដាលនៃជំងឺកូវីដ-១៩ ហើយបន្តធ្វើការជាមួយអង្គការសុខភាពពិភពលោក និងដៃគូអភិវឌ្ឍន៍ ដើម្បីពង្រឹងប្រព័ន្ធសុខភាពសាធារណៈ និងការត្រៀមបង្ការជំងឺរាតត្បាត ដោយផ្អែកលើបទពិសោធន៍ក្នុងឆ្នាំ២០២០ ។

(ដ) ពិនិត្យ និងបងកើតឱ្យមានកញ្ចប់ជំរុញសេដ្ឋកិច្ច ដែលឆ្លើយតបទៅនឹងតម្រូវការរបស់មនុស្សទាំងអស់ដែលប្រាក់ចំណូលរបស់ពួកគេបានរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយ ជំងឺកូវីដ-១៩ ទាំងវិស័យក្នុងប្រព័ន្ធ ទាំងវិស័យក្រៅប្រព័ន្ធ និងវាយតម្លៃដោយប្រយ័ត្នប្រយែងពីផលប៉ះពាល់ដែលអាចមានលើសិទ្ធិមនុស្ស ជាពិសេស លើអ្នកដែលងាយរងគ្រោះបំផុត ដោយសារវិធានការរឹតត្បិតដែលបានគ្រោងទុកសម្រាប់ ឆ្នាំ២០២១

(ឋ) ធានាឱ្យមានការប្រកាន់ខ្ជាប់យ៉ាងពេញលេញនូវក្របខ័ណ្ឌច្បាប់ដែលបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងនាមជាស្ថាប័នតុលាការឯករាជ្យ និងមិនលំអៀង និងធានាផងដែរថា ស្ថាប័ននេះធ្វើការស៊ើបអង្កេតពេញលេញ និងត្រឹមត្រូវជាមួយនឹងដីកាដំណោះស្រាយដែលបានឯកភាព ឈានទៅដល់ការអនុវត្តដ៏ពេញលេញបំផុតនូវសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ រួមទាំងភាពប្រាកដប្រជាតាមផ្លូវច្បាប់

(ឌ) ធានាឱ្យមានការរៀបចំ និងការបញ្ជូនរបាយការណ៍ដែលហួសកាលកំណត់ទៅស្ថាប័នសន្ធិសញ្ញាផ្សេងៗ ធ្វើបច្ចុប្បន្នភាពឯកសារស្នូលរួម រៀបចំកាលវិភាគបន្តដើម្បីការដាក់បញ្ជូនឱ្យបានទាន់ពេលវេលា និងការពិគ្រោះយោបល់បន្ត និងអនុវត្តអនុសាសន៍ទាំងឡាយដែលផ្តល់ដោយនីតិវិធីពិសេស ស្ថាប័នសន្ធិសញ្ញា និងការពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់។

(ឍ) ធ្វើបញ្ចប់ផែនការអនុវត្តសម្រាប់អនុសាសន៍ដែលបានមកពីការពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់ រួមបញ្ចូលជាបណ្តើរៗនូវអនុសាសន៍ពីយន្តការសិទ្ធិមនុស្សផ្សេងទៀត និងពិចារណារៀបចំផែនការសកម្មភាពជាតិទូលំទូលាយមួយ សម្រាប់សិទ្ធិមនុស្ស និងអនុវត្តនូវមូលដ្ឋានទិន្នន័យអនុសាសន៍ជាតិស្តីពីសិទ្ធិមនុស្ស។